# សម្ភាសន៍ជាមួយឈ្មោះ ព្រំ រិន ភេទប្រុស អាយុ៥៨ឆ្នាំ

## មុខងារសម័យខ្មែរក្រហមៈ“អនុវរសេនាធំ”

## ស្រុកកំណើតនៅភូមិចាន់ ឃុំព្រៃកណ្តៀង ស្រុកពាមរក៍ ខេត្តព្រៃវែង

## រស់នៅភូមិទួលពង្រ ឃុំទំនប់ដាច់ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្តរមានជ័យ

## ថ្ងៃទី១៨ ខែធ្នូ ឆ្នាំ២០១៣

## សម្ភាសន៍ដោយៈ សុខ វណ្ណៈ

## ០១:១៨:៤១

## ៣៤ទំព័រ

វណ្ណៈៈ ចឹងថ្ងៃទី១៨ខែ១២ឆ្នាំ២០១៣ ខ្ញុំឈ្មោះ សុខ វណ្ណៈ មកពីមជ្ឈមណ្ឌលឯកសារកម្ពុជា ខ្ញុំបានមកដល់ភូមិឃុំពូ ចង់ដឹងរឿងរ៉ាវដែលទាក់ទងនិងសម័យកាលកន្លងមក ថាបងប្អូនយើងរស់នៅរបៀបយ៉ាងម៉េចតាំងពីមុនមកដល់បច្ចុប្បន្ន មានការវិវត្តអីយ៉ាងម៉េចដែរ ចឹងបទសម្ភាសខ្ញុំជាមួយពូហ្នឹង ខាងខ្ញុំសូមយកទៅចងក្រងជាឯកសារទុកឲ្យក្មេងជំនាន់ក្រោយមកដឹងបានពូពូមិនថាអីទេ?

រិនៈ បាទ ។

វណ្ណៈៈ ជាដំបូងខ្ញុំចង់ស្គាល់ឈ្មោះពូ ពូឈ្មោះអីដែរ?

រិនៈ ព្រំ រិន ។

វណ្ណៈៈ ពូមានហៅក្រៅទេ?

រិនៈ អត់ទេ ។

វណ្ណៈៈ អាយុប៉ុន្មានហើយ?

រិនៈ ៥៨ ។

វណ្ណៈៈ ប្រពន្ធពូឈ្មោះអីដែរ?

រិនៈ សន ថុល ។

វណ្ណៈៈ គាត់អាយុប៉ុន្មានដែរ?

រិនៈ អាយុ៥៥ ។

វណ្ណៈៈ កូនចៅពូរាល់ថ្ងៃមានប៉ុន្មាននាក់?

រិនៈ មាន៨នាក់ ។

វណ្ណៈៈ ស្រីប៉ុន្មាន?

រិនៈ ស្រី៣ប្រុស៥ ។

វណ្ណៈ ពូមានស្រុកកំណើតនៅណាវិញ?

រិនៈ ស្រុកកំណើតនៅស្រុកពាមរក៍ ខេត្តព្រៃវែង ។

វណ្ណៈ ភូមិអី?

រិនៈ ភូមិចាន់ ។

វណ្ណៈ ឃុំ?

រិនៈ ព្រែកណ្ដៀង ។

វណ្ណៈ ចឹងសព្វថ្ងៃពូរស់នៅភូមិឃុំអីដែរ?

រិនៈ ភូមិទួលពន្រ ឃុំទំនប់ដាច់ ស្រុកត្រពាំងប្រាសាទ ខេត្តឧត្ដរមានជ័យ ។

វណ្ណៈ ចឹងកាលពីតូចពូបានរៀនសូត្រដល់ណាដែរ?

រិនៈ រៀនបានត្រឹមថ្នាក់ទី១០ចាស់ ខ្ញុំឈប់ចូលបដិវត្ត ។

វណ្ណៈ ចឹងពូរៀននៅសាលាណា?

រិនៈ រៀននៅភូមិកំណើតរបស់ខ្លួន ។

វណ្ណៈ សាលាទួលពន្រ?

រិនៈ អត់ទេ ។

វណ្ណៈ សាលាភូមិចាន់?

រិនៈ សាលាភូមិចាន់ ។

វណ្ណៈ ឪពុកពូឈ្មោះអីដែរ?

រិនៈ ព្រំ រ៉ែន ។

វណ្ណៈ ម្ដាយ?

រិនៈ ម្ដាយ ឈ្មោះ ប៉ាវ រួ ។

វណ្ណៈ ពូមានបងប្អូនបង្កើតប៉ុន្មាននាក់ដែរ?

រិនៈ ខ្ញុំមានបងប្អូន៨នាក់ ។

វណ្ណៈ ប្រុសប៉ុន្មានស្រីប៉ុន្មាន?

រិនៈ ប្រុស៤ស្រី៤ ។

វណ្ណៈ ចឹងបងទី១ឈ្មោះអីដែរ?

រិនៈ ខ្ញុំបងគេ ។

វណ្ណៈ ទី២?

រិនៈ ទី២ ឈ្មោះ សារ៉ុន ។

វណ្ណៈ ទី៣?

រិនៈ ទី៣ឈ្មោះ ហាន ។

វណ្ណៈ ទី៤?

រិនៈ ទី៤ ភ៉ា ។

វណ្ណៈ ទី៥?

រិនៈ ទី៥ ធា ។

វណ្ណៈ ទី៦?

រិនៈ ទី៦ រ៉េម ។

វណ្ណៈ ទី៧?

រិនៈ ស្មី ។

វណ្ណៈ ទី៨?

រិនៈ ឈ្មោះ សម្រេច ។

វណ្ណៈ ចឹងទាំង៨នាក់ហ្នឹង សព្វថ្ងៃនៅរស់ប៉ុន្មានសម្លាប់ប៉ុន្មាន?

រិនៈ អត់មានស្លាប់ទេ នៅទាំងអស់ មានប្ដីប្រពន្ធអស់ហើយ ។

វណ្ណៈ មកនៅនេះដែរឬនៅស្រុកភូមិ?

រិនៈ រស់នៅភូមិកំណើតទាំងអស់ ។

វណ្ណៈ អត់មានមករស់នៅខាងស្រុកត្រពាំងប្រាសាទជាមួយពូទេ?

រិនៈ អត់មានទេ នៅស្រុកទាំងអស់ ។

វណ្ណៈ ចឹងកាលពូឈប់រៀន ឈប់រៀននៅឆ្នាំណា?

រិនៈ ឆ្នាំ១៩៧១ ។

វណ្ណៈ ចឹងឆ្នាំរដ្ឋប្រហារឆ្នាំ១៩៧០ នៅរៀនបានចឹង?

រិនៈ នៅរៀន ដល់ឆ្នាំ៧២បានចូលធ្វើការ ធ្វើជាទ័ពស្រុក ។

វណ្ណៈ ចឹងពូឈប់ដោយសារអី ឈប់ដោយសារមានរដ្ឋប្រហារហ្នឹងឬឈប់ដោយសារអី?

រិនៈ ឈប់ដោយសាររដ្ឋប្រហារ រត់កាលហ្នឹងគេបង្កើតចលនា ។

វណ្ណៈ ចឹងពេលឈប់រៀន ពូឈប់មួយរយៈជួយធ្វើការងារឪពុកម្ដាយឬមួយយ៉ាងម៉េចដែរ?

រិនៈ នៅជាមួយឪពុកម្ដាយ ។

វណ្ណៈ ដល់ឆ្នាំ១៩៧២ បានពូស្ម័គ្រចិត្តឈប់ធ្វើការ?

រិនៈ បាទ! ធ្វើកងទ័ពស្រុកពាមរក៍ហ្នឹង ។

វណ្ណៈ៖ ចឹងយោធាស្រុក?

រិនៈ បាទ ។

វណ្ណៈ៖ ហេតុអីបានជាពូស្ម័គ្រចិត្តចូលធ្វើជាយោធាស្រុក ដោយសារមានមូលហេតុអី ដោយសារពូខឹងរដ្ឋប្រហារទម្លាក់សម្ដេចឬមួយមានមូលហេតុអីផ្សេង?

រិនៈ កាលហ្នឹងយើងស្ម័គ្រចិត្តបម្រើជាតិតែម្ដង ។

វណ្ណៈ៖ ចឹងកាលហ្នឹងអត់មានបង្ខំពូទេ?

រិនៈ បាទ!អត់មានបង្ខំទេ ។

វណ្ណៈ៖ កាលពូយោធាស្រុក កាលហ្នឹងមានគណៈស្រុកមាននៅកាលឆ្នាំ៧២ហ្នឹង?

រិនៈ មានហើយឈ្មោះ តាវែង រដ្ឋ យើងនៅម៉ាឡៃ រាល់ថ្ងៃហ្នឹង ។

វណ្ណៈ៖ គណៈស្រុកឈ្មោះ អីគេ?

រិនៈ ឈ្មោះ រដ្ឋ ។

វណ្ណៈ៖ ចឹង រដ្ឋ រាល់ហ្នឹងរាល់ថ្ងៃនៅណា?

រិនៈ នៅម៉ាឡៃ គាត់ហៅ ឈ្មោះ រដ្ឋ ផង ហៅ តាវែង ផង ។

វណ្ណៈ៖ ចឹង តាវែង ហ្នឹងគាត់ជាគណៈស្រុករហូតឬមួយមានការផ្លាស់ប្ដូគាត់ដែលតាំងពីពូស្គាល់គាត់តាំងពីឆ្នាំ១៩៧២ មកហ្នឹង?

រិនៈ គាត់ក្រោយមក ដឹងគាត់ទៅទូតការ៉េ អះ!ទូតចិន កាលហ្នឹងខ្ញុំមិនដឹងទៅឆ្នាំណាខ្ញុំភ្លេចទៅកាលហ្នឹង ដល់ក្រោយមកឆ្នាំ៧០ប៉ុន្មាន គាត់មកម៉ាឡៃ មកនៅជាមួយអ៊ំអៀង សារី វាភ្លេចឆ្នាំដែរ ។

វណ្ណៈ៖ បាទ ។

រិនៈ ទៅកាលហ្នឹងមិនដឹងជាឆ្នាំ៧៥ឬ៧៦ ។

វណ្ណៈ៖ ចឹងបែកភ្នំពេញហើយបានគាត់ទៅចិន?

រិនៈ បាទ!កាលហ្នឹងខ្ញុំឡើងមកទ័ពតំបន់ហើយកាលហ្នឹង ។

វណ្ណៈ៖ ចឹងអនុតាវែងស្គាល់ទេ?

រិនៈ ខ្ញុំភ្លេចអស់ហើយ ។

វណ្ណៈ៖ ចឹងគណៈតំបន់ពូស្គាល់ទេ?

រិនៈ មាន តែផ្លាស់ប្ដូច្រើនពេក តំបន់យើង២៨នេះគឺ មានតាជ័យ អស់ពីតាជ័យដឹងពីណា ។

វណ្ណៈ៖ តាជ័យ គាត់កាន់តាំងពីឆ្នាំណា?

រិនៈ តាជ័យ៧៨ មើលខ្ញុំរកនឹកសិន កាលហ្នឹងឆ្នាំ៧៥ ភ្លេចអស់ហើយ ។

វណ្ណៈ:	ចឹងបកមកកាលនៅយោធាស្រុកវិញ ចឹងកាលហ្នឹងប្រធានយោធាស្រុកពីណាគេ?

វិនៈ	តាបែ មេវរៈខ្ញុំ ។

វណ្ណៈ:	ចឹងរាល់ថ្ងៃគាត់នៅទេ?

វិនៈ	រាល់ថ្ងៃគាត់នៅភូមិភាគ៥ នៅបាត់ដំបង ផ្កាយមួយឥឡូវ ។

វណ្ណៈ:	ចឹងគាត់នៅភូមិភាគ៥ ?

វិនៈ	បាទ ។

វណ្ណៈ:	គាត់ឈ្មោះអីបែទៅ?

វិនៈ	ខ្ញុំនាមត្រកូលភ្លេចហើយ ។

វណ្ណៈ:	ចឹងកាលពូនៅយោធាស្រុកហ្នឹង តាបែ ជាប្រធានយោធា?

វិនៈ	បាទ ។

វណ្ណៈ:	ចឹងយោធាស្រុកហ្នឹងគេមានបង្កើតកងពលអីនៅ?

វិនៈ	អត់មានទេ មានតែយោធាស្រុកមយយវរៈហ្នឹង មានបី“គ” ។

វណ្ណៈ:	ចឹងមាន“៣គ”ហ្នឹងមានមនុស្សប្រហែលជាប៉ុន្មាននាក់?

វិនៈ	កាលហ្នឹងមួយ“គ”មាន១០០ជាងមាន១២០ទៅ១៣០នាក់ ។

វណ្ណៈ:	ចឹងវាមាន?

វិនៈ	មាន៣០០ជាងទៅ៤០០ ខ្ទង់៣៦០-៣៧០ ទ័ពកាលហ្នឹងមានពេញៗ ។

វណ្ណៈ:	ចឹងកាលហ្នឹងមានមនុស្សស្ម័គ្រចូលច្រើន?

វិនៈ	បាទ!មួយក្រុមស្មើនិង១២នាក់ ។

វណ្ណៈ:	ចឹងយោធាស្រុកគេឲ្យយើងធ្វើអីខ្លះ មានឡើងវាយជាមួយទាហាន លន់ នល់ ដែរឬក៏អត់ទេកាលហ្នឹង?

វិនៈ	វាយជាមួយទាហាន លន់ នល់ យើងការពារនៅដូនឿន ។

វណ្ណៈ:	ការពារអីគេ?

វិនៈ	ឡើងវាយនៅដូនឿនយើងនៅព្រៃវែងកាលហ្នឹង ទ័ពស្រុកពាមរក៍មិននៅមួយដូរយើងទួលទ្រៀលអីហ្នឹង ។

វណ្ណៈ:	កាលហ្នឹងវាយជាមួយទាហានលន់ នល់?

វិនៈ	បាទ!កាលហ្នឹងនៅសំរោងអីសុទ្ធតែទាហាន លន់ នល់ នៅកាលហ្នឹងឆ្នាំ៧២-៧៣-៧៤ ។

វណ្ណៈ:	ចឹងឆ្នាំ៧២-៧៣-៧៤អីហ្នឹងពូអត់មានផ្លាស់ទៅទ័ពតំបន់អីទេ?

វិនៈ	ឆ្នាំ៧៤ខ្ញុំឡើងមកទ័ពតំបន់ មកវាយអ្នកលឿងវិញ កាលហ្នឹងមកបង្កើតមួយ“ង”តែម្តង ។

វណ្ណៈ ចឹងកាលឆ្នាំ៧២-៧៣ហ្នឹងវាយនៅណាវិញ?

វិនៈ ឆ្នាំ៧៣-៧៤ហ្នឹងខ្ញុំឡើងមកទ័ពតំបន់ហើយ ទ័ពតំបន់២៤យើងនៅក្បែរអ្នកលឿង ។

វណ្ណៈ ចឹងកាលហ្នឹងវាយមកខាងអ្នកលឿង?

វិនៈ បាទ!វាយនៅម៉ុំខ្ទួតអីហ្នឹង វត្តវាលជិបងអីហ្នឹង ។

វណ្ណៈ ចឹងពេលហ្នឹងឡើងមកតំបន់មានកងពលហើយ?

វិនៈ ដូចជាមិនទាន់មានទេ គេបង្កើតជា“ង” មាន“ង១២៥ង១២៤” ។

វណ្ណៈ ចឹងមានវរសេនាធំអីទេ?

វិនៈ មានមេខ្ញុំឈ្មោះ បងឈួន តាកង ។

វណ្ណៈ ចឹងប្រធានវរសេនាធំឈ្មោះអី?

វិនៈ ឈ្មោះឈួន ។

វណ្ណៈ វរសេនាធំលេខប៉ុន្មាន?

វិនៈ វរសេនាធំលេខ១២៥ ។

វណ្ណៈ គេដាក់ចឹងតែម្តង?

វិនៈ បាទ ។

វណ្ណៈ ចឹងវរសេនាតូច?

វិនៈ ខ្ញុំនៅ“ឃ៣”វរសេនាតូច កាលហ្នឹងគេហៅ“ឃ” ខ្ញុំនៅ“គ១០” ។

វណ្ណៈ ចឹងមាន“គ១០”ទៀត?

វិនៈ បាទ ។

វណ្ណៈ យ៉ាងម៉េចបានគេហៅចឹងពូ?

វិនៈ ពីដើមគេហៅចឹងគេមិនហៅវរសេនាតូចទេ វរសេនាតូចមាន“គ៣គ១០ចឹងទៅ” ។

វណ្ណៈ បាទ ។

វិនៈ មួយ“ង១២៥”ហ្នឹង ដល់ឆ្នាំ៧៥ខ្ញុំបានឡើងកងពលមជ្ឈិមបក្ស៨០៥របស់មជ្ឈិមបក្សគេប្រាប់ចូលគ្នា ។

វណ្ណៈ កងពលប៉ុន្មាន?

វិនៈ លេខ៨០៥ របស់មជ្ឈិមបក្សខ្ញុំនៅកងពលពិសេសកាលហ្នឹង ក្រោយមកគាត់គេចាប់ហើយមេ“ង”ហ្នឹង ចាប់យកទៅសម្លាប់ចោលអស់ ឆ្នាំ៧៥-៧៦ ។

វណ្ណៈ ចាំមើលកងពល៨០៥ហ្នឹងកងពិសេសចឹងប្រធានកងពលពីណាគេ?

វិនៈ បងសុខ សារឿន នៅភូមិភាគ៤នេះ ។

វណ្ណៈ	ចឹង?

រិនៈ	បាទ!ហ្នឹងមេរបស់សម្តេច ហ៊ុន សែន ខ្ញុំមានលេខគាត់នៅខ្ញុំ គាត់គេមកខ្ញុំរកសុំអង្ករមួយ “បេ” ។

វណ្ណៈ	យ៉ាងម៉េចបានសុំពូវិញ?

រិនៈ	អត់ទេ ខ្ញុំគេសុំគាត់ ។

វណ្ណៈ	អូ!សុំគាត់ទេ?

រិនៈ	បាទ ។

វណ្ណៈ	ចឹងឈ្មោះ សុខ សារឿន ហ្នឹងសម័យតស៊ូ គាត់ជាមេសម្តេចទៀត?

រិនៈ	បាទ!មេ ។

វណ្ណៈ	លេខគាត់លេខប៉ុន្មាន?

រិនៈ	០៩៧ ។

វណ្ណៈ	ឥឡូវគាត់ឧត្តមសេនីយ?

រិនៈ	បាទ!ឧត្តមសេនីយផ្កាយ២ ។

វណ្ណៈ	០៩៧៩៨៨៨០០០ ។

រិនៈ	បាទ ។

វណ្ណៈ	ចឹងគាត់មានសំណាងដែរ ពេលសម័យតស៊ូរយៈពេលប៉ុន្មានឆ្នាំហ្នឹងគាត់អាចរស់បាន ចឹងខាងហ្នឹងខាងភូមិភាគបូព៌ាតើ?

រិនៈ	បាទ!គាត់ជាប់គុកតើ យួនយកដាក់គុកនៅព្រៃសមួយរយៈដែរ ។

វណ្ណៈ	ម៉េចបានយួនយកដាក់គុកនៅព្រៃស?

រិនៈ	ដល់ក្រោយរួច រួចមិនដឹងជារួចឆ្នាំណា ។

វណ្ណៈ	មិនមែនយួនទេ?

រិនៈ	យួនចាប់ ចាប់បានយើងនៅខាងភ្នំទិវ៉ាល់អីហ្នឹង ចេញមកសារភាពមកហ្នឹង ។

វណ្ណៈ	ចឹងចាប់ក្រោយ៧៩ចឹង?

រិនៈ	បាទ!ចាប់ឆ្នាំ៧៩ហ្នឹងហើយ ។

វណ្ណៈ	ចឹងកាលហ្នឹងប្រធានភូមិភាគពីណាគេ សម័យ៧៤-៧៥សម័យតស៊ូហ្នឹង?

រិនៈ	តាភីមហ្នឹង ។

វណ្ណៈ	សោភីម?

រិនៈ	បាទ ។

វណ្ណៈៈ	គាត់កាន់ទ័ពទេ សោភឹម?

វិនៈ	គាត់កាន់ភូមិភាគតែម្ដង ភូមិភាគបូព៌ាយើងជាមួយ យាយការ៉ូ ប្រពន្ធគាត់ គាត់មួយភូមិភាគ លើគាត់ហើយ ភូមិភាគបូព៌ាហ្នឹង យាយការ៉ូប្រពន្ធគាត់ នៅទួលព្រាបអីហ្នឹង ។

វណ្ណៈៈ	ចឹងបន្ទាប់ពី សោភឹម មានពីណាគេ?

វិនៈ	ខ្ញុំមិនសូវស្គាល់ទេ ស្គាល់តែតាភឹម មួយនិងយាយការ៉ូ ។

វណ្ណៈៈ	ចឹងពូនិយាយថា ប្រធានវរសេនាធំឈ្មោះ ឈួន អីហ្នឹងគេសម្លាប់គាត់ក្រោយមក?

វិនៈ	ឆ្នាំ៧៦គេចាប់យកទៅសម្លាប់ចោលអស់ ក្រោយមកបងសុខ សារឿន ហ្នឹងគាត់ឡើង ប្រធានកងពល៨០៥របស់មជ្ឈឹមហ្នឹង យកពីភូមិភាគទៅយកទៅក្ដាប់ហ្នឹង ។

វណ្ណៈៈ	ចឹងឈួន ហ្នឹងអន្ដការចាប់?

វិនៈ	បាទ!អន្ដការចាប់៧៦ ។

វណ្ណៈៈ	យ៉ាងម៉េចបានពូដឹងថាចាប់?

វិនៈ	ចុះបើខ្ញុំនៅកងពិសេសជាមួយគាត់ គេហៅយកទៅរៀនតែម្ដងទៅរៀនៗបាត់តែម្ដងក្រោយ មកបានបញ្ជូនមកបងសុខ សារឿន យកមកកាន់កាប់វរសេនាតូចវរសេនាធំអី ។

វណ្ណៈៈ	ចឹងកាលគេចាប់តាឈួន ហ្នឹងកាលហ្នឹងគេតាមចាប់ សោភឹម ហើយនៅ?

វិនៈ	នៅទេ កាលហ្នឹង យកតាមតំបន់ទៅសិន ។

វណ្ណៈៈ	ចឹងកាលឆ្នាំ៧៦ហ្នឹង ចាប់គ្នាច្រើនដែលអត់ពូ?

វិនៈ	ចាប់ច្រើនតាមវរៈចាប់ទាំងអស់ វរសេនាតូចវរសេនាធំអី ចាប់យកទៅទាំងអស់យកទៅរៀន សូត្រហ្នឹង ។

វណ្ណៈៈ	ចឹងកាលហ្នឹងពូអត់អីដែរ?

វិនៈ	ខ្ញុំកូនចៅគេត្រឹមប្រធាន“ខ”មានអីប្រធានក្រុម ។

វណ្ណៈៈ	ចឹងពូត្រឹមប្រធាន“ខ”?

វិនៈ	បាទ ។

វណ្ណៈៈ	ប្រធាន“ខ”ស្មើអីយ៉ាងម៉េចទៅ?

វិនៈ	ត្រឹមកងតូចលើប្រធានក្រុម ។

វណ្ណៈៈ	ហ្នឹងគេហៅប្រធានកងតូច?

វិនៈ	បាទ!កងតូច ។

វណ្ណៈៈ	កងតូចមានគ្នាប៉ុន្មាននាក់?

វិនៈ	កងតូចមាន៣០នាក់ គិតទៅ៤៨វាក្នុងមួយក្រុម១២នាក់ ។

វណ្ណៈ៖ ចឹងខ្ញុំចង់សួរបកទៅវិញ កាលខាងភូមិភាគបូព៌ាវាយចូលទីក្រុងភ្នំពេញហ្នឹង ពូចូលមកតាមផ្លូវណាចូលមកភ្នំពេញ?

រិនៈ ខ្ញុំអត់ទេ ខ្ញុំចូលត្រឹមអ្នកលឿងទេ ។

វណ្ណៈ៖ ចឹងចូលត្រឹមអ្នកលឿង?

រិនៈ បាទ ។

វណ្ណៈ៖ ចឹងពូថាខាងភូមិភាគបូព៌ាចូលភ្នំពេញក្រោយគេ?

រិនៈ អាហ្នឹងខាងភូមិភាគគេផ្សេងៗ ដូចជាកងពលទី១អីគេទៅខាងភ្នំពេញ កងពល៥៧០អីហ្នឹងពួកតាកែវពួកអីវ៉ាន់ហ្នឹង ។

វណ្ណៈ៖ ចឹងមានន័យថាខាងភូមិភាគបូព៌ាមិនបានចូលភ្នំពេញឆ្នាំ៧៥ហ្នឹងទេ?

រិនៈ អត់បានទេ នៅត្រឹមអ្នកលឿងទេ ។

វណ្ណៈ៖ ចឹងបានជាខាងតាម៉ុក ចង់ចោទថា ចង់ទាក់ទងជាមួយវៀតណាមអីណា ខាងបូព៌ាហ្នឹងមិនបានចូលដល់ទីក្រុងភ្នំពេញទេចឹង?

រិនៈ អត់បាន ។

វណ្ណៈ៖ ចឹងកងពលផ្សេងៗទៀតចូលដល់?

រិនៈ បាទ!ខ្ញុំមិនទាន់កើតកងពលទេ ត្រឹមវរសេនាធំទេ វាមានពីរវរសេនាធំទេ“៥១២៥-៥១២៨”ដណ្តើមយកអ្នកលឿងបានពីសាធារណរដ្ឋលន់ នល់ កាលហ្នឹងទាហាន លន់ នល់ ។

វណ្ណៈ៖ ចឹងយ៉ាងម៉េចបានចូលត្រឹមអ្នកលឿងគេបែកតែម្តង?

រិនៈ បាទ!បែក ចុះគេលើកទង់ជ័យចុះចូលយើងហើយ ចុះទីក្រុងភ្នំពេញឈ្នះហើយ ។

វណ្ណៈ៖ ចឹងពេលភ្នំពេញជ័យហើយកម្លាំងរបស់ពូឆ្នាំ១៩៧៥ហ្នឹង ត្រូវគេបញ្ជូនមកភ្នំពេញដែរឬមួយគេបញ្ជូនឡើងមកខាងណាវិញ?

រិនៈ ទៅខាងព្រំដែនយួនតែម្តង ។

វណ្ណៈ៖ ចឹងពូទៅខាងព្រំដែនខាងស្វាយរៀង?

រិនៈ នេះខាងម៉ាដូរយើងស្រុកពាមជរ ស្រុកព្រះស្តេច ។

វណ្ណៈ៖ ឆ្នាំ៧៥ហ្នឹង?

រិនៈ បាទ!ហ្នឹងចាប់ផ្តើមធ្វើស្រែហើយណា ។

វណ្ណៈ៖ ការពារព្រំដែនយួន?

រិនៈ បាទ!ការពារព្រំដែនយួន ។

វណ្ណៈ៖ ចឹងការពារផងធ្វើស្រែផង?

រិនៈ បាទ! ធ្វើស្រែខ្លួនឯងម្ចាស់ការ ។

វណ្ណៈ កាលហ្នឹងប៉ុន្មានវរៈឬមួយម៉ាកងពល?

រិនៈ វាពីរវរសេនាធំ ។

វណ្ណៈ ពីរវរសេនាធំមានគ្នាប្រហែលជាប៉ុន្មាននាក់?

រិនៈ ពីរវរសេនាធំមិនធម្មតាទេ ច្រើនរាប់ម៉ឺនដឹង មិនមែនដូចទ័ពឥឡូវទេ វរៈកាលហ្នឹងពេញៗល្អណាស់ សឹងថា៥០០០មួយវរសេនាធំ មួយវរសេនាតូចអីមាន៨០០ជាងហើយ ។

វណ្ណៈ ចឹងប្រធានវរសេនាធំទាំងពីរហ្នឹងឈ្មោះអីគេទៅ?

រិនៈ ឈ្មោះ ប៊ុន ហួយ វរសេនាធំខ្ញុំឈ្មោះ ប៊ុន ហួយ ។

វណ្ណៈ ប្រធានវរសេនាធំលេខប៉ុន្មាន?

រិនៈ លេខវរសេនាធំ១៧០ គេផ្លាស់ហើយហ្នឹង ។

វណ្ណៈ ចឹងមួយទៀត?

រិនៈ បងសុខ សារឿន មិញហ្នឹង វរសេនាធំ"ង១៧១" ។

វណ្ណៈ ចឹងក្រែងគាត់បានឡើងជាប្រធានកងពល?

រិនៈ ហ្នឹងនៅឡើយទេ ។

វណ្ណៈ ចឹងនៅទេ?

រិនៈ បាទ! នៅការពារព្រំដែនហើយ ។

វណ្ណៈ ចឹងឆ្នាំណាបានគាត់ឡើងប្រធានកងពល?

រិនៈ ឆ្នាំ១៩៧៨ ។

វណ្ណៈ ចឹងគាត់នៅការពារព្រំដែនដែរ?

រិនៈ បាទ!គាត់នៅព្រំដែនដែរ ព្រំដែនវៀតណាម កាលហ្នឹងគេចាប់ តាឈួន ទៅរៀនទៅគាត់ឡើងជំនួស តាឈួន ហ្នឹង ។

វណ្ណៈ ចឹងយាយការ៉ូអីហ្នឹងគេចាប់គាត់ពូមានដឹងទេ?

រិនៈ អត់ដឹងទេ ។

វណ្ណៈ ចឹងតាសោភឹម ហ្នឹងគេតាមចាប់គាត់ពូបានដឹងទេ?

រិនៈ ខ្ញុំអត់ដឹងទេ ។

វណ្ណៈ ចឹងកាលពូនៅជាយដែនហ្នឹងគេឲ្យធ្វើស្រែនិងការពារ?

រិនៈ បាទ ។

វណ្ណៈ នៅម្តុំភូមិអីទៅ?

រិនៈ នៅត្រង់ហ្នឹងគេហៅទួលតាប៉ុល ឃុំទាមទារ កាលហ្នឹង ស្រុកព្រះស្តេច ខេត្តព្រៃវែង ។

វណ្ណៈ ចឹងស្រុកព្រះស្តេច?

រិនៈ បាទ ។

វណ្ណៈ ចឹងពូនៅការពារហ្នឹងរហូតដល់៧៩ឬមួយមានការផ្លាស់ប្តូរទៀត?

រិនៈ នៅដល់ឆ្នាំ៧៩រហូតដល់យួនវាយរត់ឆ្លងទន្លេវៀងខ្ទួន ។

វណ្ណៈ ចឹងបើតាមឯកសារខាងភូមិភាគបូព៌ាត្រូវបានខាងភូមិភាគនិរតីចូលទៅបោសសម្អាតច្រើន?

រិនៈ បាទ!នៅឆ្នាំ១៩៧៨ ។

វណ្ណៈ ចឹងនៅឆ្នាំ១៩៧៨ ពូមានដឹងថា មានការចាប់មនុស្ស មានសម្លាប់មនុស្សពូមានដឹងទេ?

រិនៈ ខ្ញុំដឹងដែរ តែខ្ញុំនៅជាយដែននោះ នៅព្រំដែនយួនរហូត ។

វណ្ណៈ ចឹងកាលពូនៅជាយដែនហ្នឹងគេមានទៅយកកម្លាំងពីហ្នឹងមកឲ្យរៀនសូត្រអីទេ?

រិនៈ អត់ទេ កងទ័ពនៅដដែល ។

វណ្ណៈ ចឹងកងទ័ពនៅដដែល?

រិនៈ បាទ!កាលហ្នឹងសម្លាប់តែពួក សោភឹម ទេជំនាន់ហ្នឹង ។

វណ្ណៈ ចឹងពូមិនមែននៅជាមួយ សោភឹម ទេ?

រិនៈ ខ្ញុំនៅខាងសោភឹមដែលតែខ្ញុំនៅខាងព្រំដែនខ្ញុំអត់មានបញ្ហាអីទេ គេចាប់អ្នកនៅក្នុងកងពលបង សិរិន នេះ កាលហ្នឹងគេភូមិភាគ៤អះ!កងពលលេខ៤ ។

វណ្ណៈ ពីណាគេ?

រិនៈ តាហេង សិរិន កាលហ្នឹងគេតាមចាប់គាត់ កាលហ្នឹងគាត់មិនភាសខ្លួនទៅយួន ។

វណ្ណៈ បាទ!កាលហ្នឹង តាហេង សិរិន កាលហ្នឹងគាត់ធ្វើអី?

រិនៈ គាត់កាន់កងពល ។

វណ្ណៈ កងពលលេខប៉ុន្មាន?

រិនៈ កងពលលេខ៤ ។

វណ្ណៈ ចឹងឆ្នាំណាដែលគាត់បានឡើងកងពលហ្នឹង?

រិនៈ មិនដឹងឆ្នាំណាទេ ខ្ញុំនៅភូមិភាគខ្ញុំនៅទ័ពតំបន់កាលហ្នឹង ។

វណ្ណៈ ឆ្នាំ៧៥-៧៦-៧៧អីហ្នឹង?

រិនៈ មុនហ្នឹងទៀតតាហ្នឹង គាត់កាន់កងពល ។

វណ្ណៈ ចឹងគាត់កាន់នៅខាងណា?

រិនៈ កាន់ខាងបូព៌ាយើងហ្នឹង បើ ជា ស៊ីម គាត់នៅគណៈតំបន់ទេ ។

វណ្ណៈ៖ គាត់មិនទាន់ឡើងជា គណៈតំបន់ទេ គាត់នៅត្រឹមគណៈស្រុកទេ?

រិនៈ ទេ គណៈតំបន់ហើយ តំបន់២១យើងនេះ ។

វណ្ណៈ៖ ខ្វះថាគាត់ត្រឹមគណៈស្រុកទេ?

រិនៈ តាមពួកហ្នឹងនិយាយថា គណៈតំបន់ បើសួរបងសុខ សារឿន ដឹង គាត់ភូមិភាគដែរ ។

វណ្ណៈ៖ ចឹងសម្តេច ហេង សំរិន គាត់ប្រធានកងពល តែគេតាមចាប់ខ្លួនគាត់ដែរ?

រិនៈ បាទ!ចឹងហើយបានគាត់រត់ទៅវៀតណាម ។

វណ្ណៈ៖ រត់ទៅវៀតណាមឆ្នាំណាពូមានដឹងទេ?

រិនៈ ឆ្នាំ១៩៧៨ហ្នឹង ពេលនិរតីចូលកាប់សម្លាប់នោះណា ។

វណ្ណៈ៖ ចឹងកាលហ្នឹងបើសិនជាគាត់នៅស្លាប់ដែរ?

រិនៈ បើគាត់នៅស្លាប់ហើយ ។

វណ្ណៈ៖ ចឹងសម្តេចជា ស៊ីម គាត់?

រិនៈ ពួខ្ញុំនិយាយថា គាត់ជាគណៈតំបន់២០-២១មិនដឹង ។

វណ្ណៈ៖ គណៈតំបន់២១គេតាមចាប់ដែរ?

រិនៈ ហ្នឹងហើយតាមចាប់ដែរ គាត់រត់ទៅវៀតណាម ។

វណ្ណៈ៖ ចឹងកាលហ្នឹងសម្តេច ហ៊ុន សេន នៅមានឋានៈតូចជាងគេ?

រិនៈ កាលហ្នឹងមិនថាធ្វើស្អីទេ ខ្ញុំមិនសូវដឹងដែរ គាត់នៅក្រោមទេ ។

វណ្ណៈ៖ គាត់ត្រឹមប្រធានតូចតាច?

រិនៈ បាទ ។

វណ្ណៈ៖ តាប៉ុល សារឿន អីបានគាត់ធំកាលហ្នឹង?

រិនៈ បាទ ។

វណ្ណៈ៖ តែពួកគាត់បានរត់ទៅវៀតណាមទាន់ បើសិនជាមិនរត់គេចាប់ទាំងអស់មួយខ្សែហ្នឹង?

រិនៈ បាទ!គេចាប់សម្លាប់ចោលទាំងអស់ ។

វណ្ណៈ៖ ចឹងកាលពូការពារនៅព្រំដែនហើយវាយគ្នារហូតដល់ឆ្នាំ១៩៧៩ហ្នឹង កម្លាំងរបស់យើងមាន គ្រោះថ្នាក់ច្រើនដែរឬមិនសូវទេ?

រិនៈ យី!ស្លាប់ច្រើនណាស់ ឆ្នាំ៧៦ហ្នឹងវាយខ្លាំង ។

វណ្ណៈ៖ ចឹងវាយតាំងពីឆ្នាំ៧៦ដែរ?

រិនៈ វាយជាមួយវៀតណាមហ្នឹងស្លាប់ច្រើនខ្មែរយើង ស្លាប់អ្នកធ្វើដើមនិងអ្នកការពារព្រំដែនហ្នឹង ឆ្នាំ៧៦ចាប់ផ្តើមប្រឈមមុខដាក់គ្នាឆ្នាំ៧៦-៧៧ហ្នឹងវាយគ្នាខ្លាំង ។

វណ្ណៈ	ចឹងវាយគ្នាតាំងពី៧៦រហូតដល់៧៩?

រិនៈ	បាទ ។

វណ្ណៈ	ចឹងអត់មានសម្រាកទេ?

រិនៈ	អត់មានសម្រាកទេ លែងចង់បានធ្វើស្រែហើយកាលហ្នឹងបានតែ៧៥ហ្នឹង៧៦ធ្វើស្រែបន្តិចបន្តួចហ្នឹង ។

វណ្ណៈ	ខ្ញុំស្មានតែឈ្លូសជាមួយវៀតណាមហ្នឹងឆ្នាំ៧៨ទៅទេ ព្រោះអីដូចឆ្នាំ៧៥-៧៦ហ្នឹងមានទូតវៀតណាមនៅស្រុកខ្មែរដែរ កាលសម័យខ្មែរក្រហម តែប្រហែលជាដកនៅពេលមានជម្លោះហ្នឹងតែម្តង ។

រិនៈ	បាទ!ខ្វង់ឆ្នាំ៧៦ហ្នឹង ក្រោយមកដេញចេញបណ្តោយទូត ។

វណ្ណៈ	ចឹងកាលនៅទល់ដែនគេឲ្យពូមានតំណែងអីខ្លះដែរ?

រិនៈ	ខ្ញុំបានកងពិសេសដដែលនៅកងពលធំកងពល៨០៥ ។

វណ្ណៈ	ចឹងនៅជាមួយតាសុខ សារឿន ហ្នឹង?

រិនៈ	បាទ!សុខ សារឿន ហ្នឹង គេហៅសុខ សេង ទើបប្រែឥឡូវទេ ខ្ញុំនៅកងពលពិសេសកងពលគាត់ ។

វណ្ណៈ	ចឹងពូគាត់មានឋានៈអីដែលជាប្រធានវរសេនាតូចវរសេនាធំអីដែរ?

រិនៈ	អត់ទេ អនុសេនាធំ ។

វណ្ណៈ	អនុសេនាធំ?

រិនៈ	បាទ ។

វណ្ណៈ	ចឹងប្រធានអនុសេនាធំផ្សេងអនុសេនាធំផ្សេង?

រិនៈ	បាទ!ប្រធានគេផ្សេងយើងរងគេ ។

វណ្ណៈ	ចឹងគេអត់ហៅប្រធានអនុសេនាធំទេ?

រិនៈ	បាទ!គេហៅរងទេ ខ្ញុំត្រឹមសក្តិ២អីហ្នឹង សក្តិ៣គេប្រធាន“គ” ។

វណ្ណៈ	ចឹងកាលហ្នឹងអាវុធអីគេបានមកពីណា?

រិនៈ	បានមកពីចិន ។

វណ្ណៈ	ឥឡូវយើងក៏ចិន?

រិនៈ	បាទ ។

វណ្ណៈ	ចឹងកាលហ្នឹងតាសុខ សារឿន អីគាត់បានរួចខ្លួនដែលគាត់អត់មានរត់ទៅវៀតណាមទេ?

រិនៈ	អត់ទេ ពេលក្រោយមកគ្មានរត់ទេ វាយចាញ់យួនរត់ទាំងអស់គ្នាតែម្តង ។

វណ្ណៈ	ចឹងពេលឆ្នាំ១៩៧៩ហ្នឹង ពេលវៀតណាមចូលមកហ្នឹងអត់មានភាសខ្លួនទៅផ្ទះ អត់មានបោះកាំភ្លើងចោលចូលទៅផ្ទះទេ?
រិនៈ	អត់ទេ រត់ឆ្លងទន្លេមេគង្គកាប់ដើមចេកឆ្លងវាយយួនឆ្លងផ្លូវគើ កាលហ្នឹងទៅកោះរកានេះ ។
វណ្ណៈ	ចឹងរត់មកជាយដែនវិញ?
រិនៈ	បាទ!រត់មកជាយដែន ។
វណ្ណៈ	យ៉ាងម៉េចបានជាពូមិនសម្រេចចិត្តចូលផ្ទះ ព្រោះអីឆ្លងកាត់ផ្លូវតាមផ្ទះដែរ?
រិនៈ	ព្រោះអីចាញ់ឃោសនាខបាយកលគេ ថាមកវៀតណាមសម្លាប់ចឹងចេះតែទៅតាមគេទៅ ចុះជឿជាក់លើអង្គការទៅហើយ ។
វណ្ណៈ	ចឹងពេលពូរត់តាមផ្លូវមានហែលទឹកចឹងមានគ្រោះថ្នាក់ថែមទៀតដែរ?
រិនៈ	មានព្រោះអាម៉ារិនយួនវាបរកិនអីណា ពេលឆ្លងមេគង្គ ។
វណ្ណៈ	យើងអត់មានលើកដៃសុំចុះចូលទេ?
រិនៈ	អត់ទេ កាលនោះមានតែបាញ់គេថែមទៀត យើងនៅក្នុងទឹកនោះ ។
វណ្ណៈ	បាញ់គេថែមទៀត?
រិនៈ	បាញ់បេ បាញ់អាម៉ារិនគេ ចុះម៉ារិនគេធំៗ បើកគៀលិចទឹកផាប់ក៏មាន មនុស្សហែលពេញទន្លេតែម្តង កងទ័ពហ្នឹង កាំភ្លើងដាក់សុទ្ធលើនេះបាញ់ទៀត ។
វណ្ណៈ	យើងហែលដើមចេកសោះហ្នឹង?
រិនៈ	ដើមចេក អោបដើមចេកខ្លះពីរខ្លះមួយទៅ ហែលឡើងច្រាំង ។
វណ្ណៈ	ចឹងវេទនាដែលឆ្នាំ៧៩?
រិនៈ	វេទនាណាស់ ។
វណ្ណៈ	ហែលដើមចេកហើយខ្លាំងទៀត?
រិនៈ	ខ្លាំង ។
វណ្ណៈ	បាញ់គេថែមទៀត យើងចាញ់ហើយហ្នឹង?
រិនៈ	បាទ ។
វណ្ណៈ	ចឹងកាលហ្នឹងបើយើងចុះចូលយើងធូរជាងតែយើងមិនដឹង?
រិនៈ	បាទ!ចេះតាមគេតាមឯងទៅតាមមេតាមកូន ។
វណ្ណៈ	ចឹងតាសុខ សារឿន គាត់រត់តាមណាដែរ?
រិនៈ	រត់តាមហ្នឹងហែលទឹកដែលហ្នឹង ។
វណ្ណៈ	ចឹងគាត់ហែលទឹកដែរ?

រិនៈ បាទ!ហែលទៅមុនខ្ញុំ ខ្ញុំបានទៅជួបគាត់នៅស្រុក១៨ចឹងទៅ ជួបជុំគ្នាការពារគាត់ទៅទៀតទៅ ដល់វាយក្បែរទន្លេបាសាក់នោះវាយនៅហ្នឹងទៀត វាយឃ្លួនឡើងប៉ើងរត់ចុះកងទ័ពវាច្រើន ឡើងខ្លះទ័ពរាប់ម៉ឺននាក់ មិនដឹងទ័ពពីណាៗទេ ។

វណ្ណៈ: ចឹងកាលពូឆ្លងតាមអ្នកលឿងវិញ?

រិនៈ ឆ្លងឡើងតាមទន្លេបាសាក់ហ្នឹង ។

វណ្ណៈ: ចឹងឡើងតាមទន្លេបាសាក់?

រិនៈ បាទ!ឡើងទៅខាងភ្នំទិវ៉ាល់អីហ្នឹង ។

វណ្ណៈ: ចឹងពេលឡើងគោករត់ឡើងទៅខាងទិវ៉ាល់ទៀត?

រិនៈ បាទ ។

វណ្ណៈ: ចឹងមានរត់បែកគ្នាដែលឬមួយរត់ទៅទាំងហ្វូងដែរ?

រិនៈ រត់ទៅទាំងហ្វូងទាំងស្រីខាងរោងចក្រអីហ្នឹងរត់ឃ្លូរៗចោលខោអាវអស់ហើយយកវាមិនរួច ។

វណ្ណៈ: ចឹងពេលឆ្លងទន្លេបាក់សាក់ហើយយើងរត់តាមភ្នំអីទៀត?

រិនៈ បាទ ។

វណ្ណៈ: ពូរត់បានរយៈពេលប៉ុន្មានដែរ បានទៅដល់ជាយដែនតែម្តង?

រិនៈ រត់រាប់ខែ ។

វណ្ណៈ: ចឹងរត់រាប់ខែ រត់ផងវាយអីចឹង?

រិនៈ បាទ!រត់ផងវាយផង ។

វណ្ណៈ: ចឹងនៅតាមផ្លូវមានឃើញមនុស្សស្លាប់ច្រើនទេ?

រិនៈ មានមនុស្សស្លាប់ច្រើនណាស់ ស្លាប់និងអត់បាយ ឃ្លួនបាញ់ខ្លះ ។

វណ្ណៈ: ចឹងពេលរត់ស្លាប់៧/៩ហ្នឹងអាចអស់មនុស្សរាប់សែនទៀតមិនស្រួល?

រិនៈ បាទ!រាប់ពាន់រាប់ម៉ឺននាក់ហ្នឹង យូរចោលអស់រោងចក្រស្រីៗវ៉ាន់អិហ្នឹងអូស ។

វណ្ណៈ: កាលហ្នឹងពូមិនទាន់មានគ្រួសារទេ?

រិនៈ នៅលីវ កងទ័ពដោយកងទ័ពជួនកាលចិញ្ចឹមពួករោងចក្រហ្នឹងដើរអង្គរឲ្យគេ ។

វណ្ណៈ: តាមព្រៃហ្នឹង?

រិនៈ បាទ!ទៅដល់ពួកនិរតីហ្នឹងរកសម្លាប់ទៀត ឃើញកងទ័ពពួកបូព៌ាមិនបានទេជំនាន់ហ្នឹង កាប់សម្លាប់គ្នាបាញ់គ្នាចោល យូរៗខ្លាចគ្នាឯងហ្នឹង ។

វណ្ណៈ: ចឹងខ្លាចគ្នាឯងទៀត?

វិនៈ បាទ!យួនលែងសូវខ្លាច ខ្លាចគ្នាឯង ចុះវាមកឃើញយើងបាញ់តែម្តង វាអត់មានសួរនាំអីទេ ពួកនិរតីហ្នឹង យើងក៏បាញ់វា វាក៏បាញ់យើង គេហៅកងពល៩៧០ម៉េចនោះ ពួកកងពលខាងតាកែវ មិនបានទេ សាហាវណាស់ ។

វណ្ណៈ ខាងតាម៉ុក ហ្នឹង?

វិនៈ បាទ!ខាងតាម៉ុក យើងក៏សម្លាប់វាដែរ ឲ្យតែឯងដាច់ហ្វូងវាយឯងចោលដែលហ្នឹង ។

វណ្ណៈ ចឹងបាញ់ទៅបាញ់មកសុទ្ធតែខ្មែរដដែល?

វិនៈ កាលមកនៅស្រុកថៃនេះវេទនាសំប៉ើមណាស់ វាអត់មានបាយអីផង លួចតែដំឡូងថៃហ្នឹង ។

វណ្ណៈ បាទ ។

វិនៈ នៅម៉ាជួរម៉ាឡៃ ម៉ាជួរបារាំងធ្លាក់ ។

វណ្ណៈ ចឹងកាលពូរត់មកដល់ដំបូងពូរត់មកដល់ម៉ាឡៃឬពូរត់មកដល់ណាមុន?

វិនៈ មកដល់ព្រៃម៉ាឡៃយើងហ្នឹង ព្រៃភ្នំគេសង់នៅព្រៃហ្នឹងឯង ។

វណ្ណៈ ចឹងមកដល់ដំបូងគេថាចាញ់ខ្លាំង?

វិនៈ ចាញ់ខ្លាំងណាស់ អាខ្លះងាប់លើអគ្រឹងទៅវាអត់មានអីហូប ។

វណ្ណៈ ចឹងមកដល់ថៃអត់មានអង្គការសហប្រជាជាតិមកជួយទាន់ទេ ដូចជាខាងកាកបាទក្រហមអីហ្នឹងកាលហ្នឹង?

វិនៈ អត់ទេ ជំនាន់ហ្នឹងដល់៨០-៨១បានខាងរដ្ឋាភិបាលប៉ុល ពត តាខៀវ សំផន ចុះមកទាក់ទងគ្នាជាមួយថៃអីហ្នឹងបានទៅ បានដឹកអង្ករអីមក បានចែកគ្នាបន្តិចៗដើម្បីបានបបរហ្នឹង ។

វណ្ណៈ បាទ ។

វិនៈ កាលហ្នឹងលួចគោថៃ លួចដំឡូងថៃ អំពៅអីហ្នឹង ថៃមិនហ៊ានជាមួយខ្មែរក្រហមទេ កាលជំនាន់ហ្នឹង ខ្មែរក្រហមបាញ់ ។

វណ្ណៈ ថៃមិនហ៊ានដែរ?

វិនៈ មិនហ៊ាន ចុះយើងសុទ្ធតែអាវុធ តែរញ៉េរញ៉ៃបាញ់ គោកំពង់ទឹមទៅដោះពីនឹមយកវាយស៊ីក៏មានដែរ ។

វណ្ណៈ គោថៃ?

វិនៈ បាទ ។

វណ្ណៈ ចឹងកាលហ្នឹងអត់ហើយ?

វិនៈ អត់ហើយ ។

វណ្ណៈ ចឹងកាលពូនៅម៉ាឡៃ កាលជំនាន់ហ្នឹងមានសម្តេចតាចុះមកដែលតើ?

រិនៈ ចុះមក ។

វណ្ណៈ ចឹងកាលមកសាតាំងអីពូមានដឹងទេ?

រិនៈ ដឹងតើ មកកាលហ្នឹងកងទ័ពទៅចូលរួម ។

វណ្ណៈ ចឹងពូមានបានចូលរួមទេ?

រិនៈ បាទ!បានក្រុមគ្រួសារទាំងអស់ហ្នឹង ។

វណ្ណៈ ចឹងឆ្នាំណាដែលពូបានចូលរួម?

រិនៈ បានចូលរួមឆ្នាំ៨៦-៨៧អីហ្នឹង សម្ដេចតាមក មកទាំងចិនមកទាំងអីទៀត មកបីដងសម្ដេចតាមកម៉ាឡៃហ្នឹង កងទ័ពដកពីមុខអីអស់ហើយមកទទួលសម្ដេចតា រៀបជាជួរ ។

វណ្ណៈ ចឹងបីដងឆ្នាំណាខ្លះពូមានចាំទេ?

រិនៈ ឆ្នាំ៨៦-៨៧ហ្នឹង ។

វណ្ណៈ ចឹងគាត់មកហ្នឹងគាត់មាននិយាយអី មានគោលការណ៍ឲ្យយើងស្ដាប់យ៉ាងម៉េចខ្លះទេ?

រិនៈ និយាយថា កូនចៅរួបរួមគ្នាសាមគ្គីគ្នាចឹងទៅ ប្រឹងប្រែងអីណា ។

វណ្ណៈ ចឹងគាត់អត់មាននិយាយថា យើងត្រូវរួបរួមគ្នាដេញយួនទៅវិញអីទេ?

រិនៈ អត់មាននិយាយទេ ។

វណ្ណៈ អត់មាននិយាយចឹងទេ?

រិនៈ បាទ!និយាយថា បានជួបកូនចៅអរណាស់ ។

វណ្ណៈ ចឹងដល់ពេលសម្ដេចមកចឹងពូបានចូលរួមប៉ុន្មានដង?

រិនៈ ខ្ញុំបានចូលរួមទាំងបីដងហ្នឹង ។

វណ្ណៈ ពូមកការពារឬមួយមកយ៉ាងម៉េច?

រិនៈ មកទទួលតែម្ដង ។

វណ្ណៈ ចឹងកាលហ្នឹងពូមានឃើញពីណាខ្លះ មានឃើញតាខៀវ សំផន តាអៀង សារី នួន ជា?

រិនៈ មកទាំងអស់ ។

វណ្ណៈ ចឹងមកជុំគ្នាទាំងអស់?

រិនៈ បាទ ។

វណ្ណៈ ចឹងតាសុន សេន?

រិនៈ សុន សេន ក៏មក ។

វណ្ណៈ ចឹងមកជួបសម្ដេចទាំងអស់នៅម៉ាឡៃហ្នឹង?

រិនៈ បាទ!ចឹងទីតាំងត្រង់ហ្នឹងវាធំ ។

វណ្ណៈ	គេហៅកន្លែងសាតាំងហ្នឹងមិនមែន?
រិនៈ	បាទ!កន្លែងសាតាំង នៅកន្លែងក្បែរចូលទៅខាងក្នុងក្បែរភ្នំហ្នឹង ។
វណ្ណៈ	ចឹងកាលសម្តេចមកគាត់ជិះមកទៅបើមានព្រៃចឹង?
រិនៈ	ជិះឡាន ថៃអបមក ។
វណ្ណៈ	ចឹងមានផ្លូវចូលមកដល់ដែរ?
រិនៈ	បាទៗ!ផ្លូវតាមស្ពានហ្នឹងចូលមកដល់ដីខ្មែរ ។
វណ្ណៈ	អ!ចូលមកត្រឹមស្ពានហ្នឹង?
រិនៈ	ចូលហួសស្ពានឆ្ងាយដែរ ពីមាត់អូរមក ។
វណ្ណៈ	មកម្តងៗមានឡានច្រើនទេ?
រិនៈ	ឡានរាប់រយនោះ មានចិន មានកូរ៉េមានអី ។
វណ្ណៈ	ចឹងអត់មានខ្លាចវៀតណាមវាយបុកចូលទេចឹង?
រិនៈ	ខ្លាចអីវៀតណាមនៅនិមិត្តនៅអីកូបនោះ វានៅតែនោះ ។
វណ្ណៈ	ចឹងវៀតណាមអត់មានវាយបុកដល់ហ្នឹងទេ?
រិនៈ	អត់ទេ!វាមិនដែលរឿងផង ព្រោះវានៅណានោះ ។
វណ្ណៈ	ចឹងសុទ្ធតែស៊ើបកម្លាំងច្បាស់ហើយថា វៀតណាមចូលមិនដល់?
រិនៈ	បាទ!ចូលណាវានៅឆ្ងាយណាស់ នៅ៣០ទៅ៤០គីឡូនៅនិមិត្តនោះ ។
វណ្ណៈ	ចឹងពូនៅម៉ាឡៃហ្នឹងតាំងពីឆ្នាំ១៩៨៦-៨៧នៅហ្នឹងរហូតចឹង?
រិនៈ	បាទ!ដល់ឆ្នាំ៨៦បានខ្ញុំមកនេះ តាម៉ុក ទៅយកមក ។
វណ្ណៈ	ចឹងកាលពូនៅម៉ាឡៃហ្នឹងគេមិនមានបង្កើតកងពលអីទៀត ពីណាប្រធានកងពលនៅហ្នឹង?
រិនៈ	តាភាព ។
វណ្ណៈ	ចឹងមានតាហុងអីទេ?
រិនៈ	បាទ! តាហុង ក្រោយមកគាត់មកកាន់កងពលខាងថ្មរយថ្មដូននេះ ។
វណ្ណៈ	នៅម៉ាឡៃកងពលលេខប៉ុន្មានទៅ?
រិនៈ	កងពល៤៥០ ។
វណ្ណៈ	ចឹងពូនៅក្នុងកងពល៤៥០?
រិនៈ	អត់ទេ ខ្ញុំនៅកងពល៥១៩ទេ គ្រាន់តែនៅហ្នឹង ។
វណ្ណៈ	កងពល៥១៩ពីណាគេប្រធានកងពល?
រិនៈ	បងសារឿន សារឿន ខ្វាក់មួយនៅថ្មរយថ្មដូនហ្នឹង ។

វណ្ណៈ៖ កងពល៥១៩នៅខាងស្វាយចេកទេ មិនមែនទេ?

រិន៖ ហ្នឹងហើយស្វាយចេកស្រែណូយអីហ្នឹង ។

វណ្ណៈ៖ កាលហ្នឹង ឌុល សារឿន?

រិន៖ បាទ!ស្អី សារឿន ទេកាលហ្នឹង ខ្ញុំភ្លេចត្រកូលគាត់ទៅ ។

វណ្ណៈ៖ ចឹងកងពល៤៥០ពីណាគេ?

រិន៖ តាភាព ។

វណ្ណៈ៖ ចឹងពូអត់មាននៅក្នុងកងពលហ្នឹងទេ?

រិន៖ អត់ទេ ខ្ញុំនៅកងពល៥១៩ ។

វណ្ណៈ៖ ចឹងកងពល៥១៩នៅម៉ាឡៃដែរ?

រិន៖ នៅម៉ាឡៃដែរ ប្រពន្ធកូនយកទៅដាក់ហ្នឹងទាំងអស់ អត់មាននៅព្រៃមាន់ភ្នំឆ័ត្រទេ ។

វណ្ណៈ៖ ចឹងប្រពន្ធកូននៅណាដែរ?

រិន៖ នៅម៉ាឡៃ ។

វណ្ណៈ៖ ចឹងពូឈរជើងនៅណា?

រិន៖ ខ្ញុំឈរជើងនៅថ្មរយថ្មដូន ។

វណ្ណៈ៖ ថ្មរយថ្មដូននៅខាងណាវិញ?

រិន៖ នៅម៉ាជួរស្រុកគោកមន ។

វណ្ណៈ៖ ចឹងគោកមនមកខាងខេត្តឧត្តរមានជ័យឬអត់ទេ?

រិន៖ អត់ទេ នៅក្នុងខេត្តបន្ទាយមានជ័យទេ ។

វណ្ណៈ៖ ខាងបន្ទាយមានជ័យ?

រិន៖ បាទ ។

វណ្ណៈ៖ យ៉ាងម៉េចបានជាប្រពន្ធនៅខាងម៉ាឡៃហើយពូឈរជើងនៅខាងនេះវិញ?

រិន៖ ចុះតាៗគាត់ឲ្យនៅខាងហ្នឹង ។

វណ្ណៈ៖ ចឹងគេហៅថ្មរយថ្មដូន?

រិន៖ បាទ ។

វណ្ណៈ៖ ពីណាប្រធានកងពល?

រិន៖ បងសារឿន ហ្នឹង ។

វណ្ណៈ៖ មិនមែនសារឿន ០៥ទេ?

រិន៖ មិនមែនទេ សារឿន ផ្សេងទៀត គាត់មាឌល្អិតទេ ខ្មៅ ខ្ទក់ក្អែកម្នាង ។

វណ្ណៈ ខ្ញុំមិនដែលបានជួបគាត់ដែរ ឥឡូវគាត់នៅណា?

រិនៈ គាត់នៅស្វាយ ។

វណ្ណៈ ចឹងនៅស្វាយ ឌុល សារឿន ហើយចឹង?

រិនៈ បាទ!គាត់តូចល្អិតមែន តែរឿងនយោបាយមិនបាច់ទេ ហូរដូចទឹកតាហ្នឹង តាសុខ អីហ្នឹង ឥឡូវគាត់នៅកងពលគាត់ តាវ៉ូយ អីហ្នឹង ។

វណ្ណៈ បាទ ។

រិនៈ តាវ៉ូយ ស្គាល់ដែរ ។

វណ្ណៈ ខ្ញុំធ្លាប់ឮឈ្មោះ ។

រិនៈ តាវ៉ូយ កងពលតូច តាវ៉ូយ វរសេនាធំទេ ។

វណ្ណៈ ចឹងពូនៅជាមួយតាវ៉ូយ នៅជាមួយតាសារឿន?

រិនៈ បាទ ។

វណ្ណៈ ចឹងតាវ៉ូយ គាត់រាល់ថ្ងៃនៅរស់ដែរ?

រិនៈ តាវ៉ូយ គាត់នៅសំរោងប្រធានកងពលរាល់ថ្ងៃ ។

វណ្ណៈ ចឹងកាលវាយជាមួយវៀតណាមជំនួយបានពីប្រទេសចិនដដែល?

រិនៈ មកពីចិនដដែល ។

វណ្ណៈ ចឹងកាលវាយគ្នាកាលហ្នឹងមានខាងវៀតណាមស្លាប់ច្រើនទេ?

រិនៈ អូ!មិនបាច់និយាយទេ រឿងវៀតណាម ។

វណ្ណៈ វៀតណាមស្លាប់ច្រើន?

រិនៈ ចុះយើងប្រើសុទ្ធតែបេ មិនសូវប្រើកាំភ្លើងអាកាហើយ ។

វណ្ណៈ ចឹងកម្លាំងប្រើចល័តទៀត?

រិនៈ បាទ!ប្រើចល័ត យើងសុខចិត្តចំណាយគ្រាប់យើងមិនសូវចំណាយកម្លាំងទេកាលហ្នឹង ។

វណ្ណៈ ចឹងចំណាយគ្រាប់ច្រើនដាង?

រិនៈ បាទ!ឃើញមួយបាញ់បេចឹង១០ដើមនោះ បាញ់ម៉ាជំនាន់នោះ ដាក់បាំងទៅសឹងថារត់មិនរួច ត្រឹមបួនប្រាំនាក់អីហ្នឹង ចង់ងាប់ទាំងអស់ ។

វណ្ណៈ ចឹងសង្គ្រាមហ្នឹង យួនក៏វាខ្លាចដែលតែមិនដឹងធ្វើយ៉ាងម៉េចភារកិច្ចរបស់វាដែរ?

រិនៈ បាទ!បញ្ហាទៅហើយ ខ្ញុំធ្វើការដល់ភ្នំស្រុកអីនោះ ស្រុកព្រះនេត្រព្រះអីនោះ បាញ់ឡានស្ទាក់ម៉ាជួរខ្មាវម៉ាជួរយើងក្រចាប់ខ្បែង សាលាក្រៅ រហូតដល់ទន្លេក្រោម ពួកខ្ញុំវាយខ្លាំងណាស់ កាលហ្នឹង ឆ្នាំ១៩៧៩នេះ ល្មមៗទប់មិនឈ្នះទេ យួនវាយដាច់ទាំងកង់ៗ ។

វណ្ណៈ	ចឹងកាលហ្នឹងអនុគាសារឿន ពីណាគេ?

រិនៈ	គាសុខ ។

វណ្ណៈ	ឥឡូវគាត់នៅទេ?

រិនៈ	គាត់នៅសំរោងដែរ នៅសំរោងបានជួបគ្នាដែលគឺ សុខ គាមៅ គារូយ គាត់ទើបឡើងកង ពលទេ គារូយ គាត់៤០៣ វរសេនាតូច អះ!វរសេនាធំ ។

វណ្ណៈ	ចឹងថាឆ្នាំណាដែលវៀតណាមវាយបុកខ្លាំងដល់ជាយដែន មានទាំងប្រជាជនអីរត់ទៅដល់ដីថៃ អីហ្នឹង ពូមានចាំទេ?

រិនៈ	វាយឆ្នាំ៨០ប៉ុន្មានទេ ។

វណ្ណៈ	ឆ្នាំ៨៥?

រិនៈ	ហ្នឹងហើយឆ្នាំ៨៥-៨៦ហ្នឹងហើយវាយខ្លាំងណាស់ វាយគាំងម៉ាឡៃអីរត់ចូលទៅនៅដីថៃទាំង អស់ ។

វណ្ណៈ	បាទ!ម៉ាជួរភ្នំដងរែកអីហ្នឹង?

រិនៈ	ទាំងអស់និយាយរួមទៅម៉ាជាយដែនកាលហ្នឹង ទៅដីថៃទាំងអស់ ។

វណ្ណៈ	ចឹងក្រោយមកខាងវៀតណាមដកទ័ពទៅវិញពូមានដឹងទេ នៅឆ្នាំណាវៀតណាមដកទ័ពទៅវិញ នៅសល់យើងវាយខ្មែរគ្នាឯងហ្នឹង?

រិនៈ	ឆ្នាំ២០០៣គាមមើល ។

វណ្ណៈ	អត់ទេ ។

រិនៈ	កាលហ្នឹងសម្ដេចមិនចូលចរចារចឹង ។

វណ្ណៈ	អត់ទេ ចរចារយើងធ្វើសមាហរណ៍កម្មក្រោយទេ ឆ្នាំ៩៨អីទេ តែពេលយើងវាយជាមួយ វៀតណាម កាលហ្នឹងមានទ័ពខាងរដ្ឋាភិបាលខាងសម្ដេចហេង សំរិន ចឹងសហការជាមួយ វៀតណាមវាយជាមួយភាគគីខាងខ្មែរក្រហម កាលនោះមានខាងគាសឺន សាន មានខាងប៉ា រាអីចឹង ប៉ុន្តែក្រោយមក ខាងវៀតណាមដកចេញទៅវិញនេះ ពូមានចាំទេ ដកចេញនៅ សល់តែខ្មែរវាយខ្មែរនោះ វៀតណាមដកកម្លាំងចេញហើយ ដោយសារមានការចរចារនៅ ប៉ារីស នៅអីហ្នឹង?

រិនៈ	អាហ្នឹងឆ្នាំ៩១ ។

វណ្ណៈ	បើតាមឯកសារវៀតណាមដកតាំងពីឆ្នាំ១៩៨៩?

រិនៈ	បាទ ។

វណ្ណៈ	តាំងពី៨៩ដល់ឆ្នាំ៩០អីហ្នឹង៩១ហ្នឹងមានការចរចារអីហ្នឹងហើយបានជាមានអ៊ុនតាក់អីហ្នឹង?

រិនៈ	កាលហ្នឹងមានតាសឺន សាន មាននរាទ្ធិ ហ្នឹងប្រួបាច់គ្នាចូល តែខ្មែរក្រហមកាលហ្នឹងមិនចូលណា ។

វណ្ណៈ	បាទ!កាលហ្នឹងខាងខ្មែរក្រហមមិនចូលទេ ។

រិនៈ	បាទ ។

វណ្ណៈ	ចឹងក្រោយមកទៀតពូថា តាម៉ុក មកយកពូនៅឆ្នាំណា?

រិនៈ	ឆ្នាំ៨៦ឆ្នាំ៨៦យកពីម៉ាឡៃមកនៅនេះ កាលហ្នឹងយកមកនៅដីថៃ នៅអណ្ដែងមុតនោះ ។

វណ្ណៈ	ចឹងកាលមិនទាន់មកខាងអន្លង់វែងទេ នៅដីថៃទេ?

រិនៈ	បាទ! នៅដីថៃទេ អន្លង់វែងមិនទាន់មានទេ សុទ្ធតែតំបន់យួននៅទេ កាលហ្នឹង ។

វណ្ណៈ	ចឹងនៅដីថៃនៅជំរុំ?

រិនៈ	នៅជំរំខ្មែរក្រហមមិនមែនជំរំកាកបាទទេ ។

វណ្ណៈ	ចឹងមិនមែននៅជំរំជនភាសខ្លួនទេ?

រិនៈ	អត់ទេ ជំរំកងទ័ព ។

វណ្ណៈ	ចឹងកាលហ្នឹងមានជំរំជនភាសខ្លួនជំរំកាកបាទក្រហម?

រិនៈ	បាទ!អានេះជំរំតាម៉ុក គាត់ទិញជំរំកងទ័ពតែម្ដង ។

វណ្ណៈ	ទិញដីថៃនៅ?

រិនៈ	បាទ!ទិញដីថៃនៅ ។

វណ្ណៈ	ចឹងទាល់តែយើងទិញគេបានធ្វើបាន?

រិនៈ	ចុះយើងព័តរបងធ្វើឃ្លាំងដាក់គ្រាប់អីនោះ ។

វណ្ណៈ	នៅម្ដុំណាហ្នឹង?

រិនៈ	នៅអណ្ដែងមុត នៅក្បែរកាប់ឆឹងយើងក្បែរប្រាសាទ ។

វណ្ណៈ	ចឹងអណ្ដែងមុតហ្នឹងស្រុកថៃទេ?

រិនៈ	បាទ! ស្រុកថៃ ។

វណ្ណៈ	តែមកខាងប្រាសាទព្រះវិហារ?

រិនៈ	មិនមែនប្រាសាទយើងទេ ប្រាសាទគេ ។

វណ្ណៈ	ចឹងនៅខាងប្រាសាទគេទេ?

រិនៈ	បាទ ។

វណ្ណៈ	ចឹងគេមានប្រាសាទដែរ?

រិនៈ	បាទ ។

វណ្ណៈ៖ ចឹងយ៉ាងម៉េចទៀតពេលបន្តបន្ទាប់មកទៀត តាម៉ុក ដឹកយកមកខាងណាទៀតដែរ ចឹងពូចេញពីគាសារឿនវិញហើយ?

រិនៈ ចេញហើយ ចេញមកនៅជាមួយតាម៉ុកវិញ ដល់យកមករៀបចំឲ្យចុះ ទៅធ្វើនយោបាយជាមួយប្រជាពលរដ្ឋយើងនៅខាងក្នុង ទៅខាងក្រែកមេមុតអីនោះ កាលហ្នឹងបីកុំ ។

វណ្ណៈ៖ បីកុំយ៉ាងម៉េចទៅ?

រិនៈ កាលដើរធ្វើនយោបាយប្រជាពលរដ្ឋកុំឲ្យលក់ស្រូវឲ្យយួនកុំទៅ«ក៥»ចឹងណាស់ ។

វណ្ណៈ៖ ចឹង?

រិនៈ បាទ! ដើរចាប់បានចឹង តាម៉ុក អប់រំទៅឲ្យលុយ៤០០០០ទៅ៥០០០០ចឹងទៅក្រណាត់មួយដុំចឹងទៅ សារ៉ុងចឹងទៅ ។

វណ្ណៈ៖ បាទ ។

រិនៈ កុំឲ្យទៅ«ក៥»កុំទៅផាប់ជួសក្បាលអាយ៉ងយួនគេពង្រឹង ។

វណ្ណៈ៖ គេនិយាយចឹងតែម្តង?

រិនៈ បាទ ។

វណ្ណៈ៖ ចឹងកាលហ្នឹងពូមកនៅខាងតាម៉ុក ពូនៅកងពលណាវិញ?

រិនៈ កាលហ្នឹងខ្ញុំនៅវរសេនាធំឯករាជ្យទេ ។

វណ្ណៈ៖ ចឹងពីណាប្រធាន?

រិនៈ តាបែ ឥឡូវ តាបែ ផ្កាយ១នៅភូមិភាគ៥រាល់ថ្ងៃហ្នឹង ។

វណ្ណៈ៖ តែនៅក្រោមបញ្ជារបស់តាម៉ុក?

រិនៈ បាទ! នៅក្រោមបញ្ជាតាម៉ុក ។

វណ្ណៈ៖ ចឹងកាលហ្នឹងដីថៃដែលទេ តែចុះមកខាងក្រោមនេះវិញ?

រិនៈ ចុះមកធ្វើការនៅខាងក្នុង ។

វណ្ណៈ៖ នៅខាង?

រិនៈ ខាងស្រែកក់បង្ហើរខ្វែង ខាងស្រុកតំបែយើងនេះ ។

វណ្ណៈ៖ ពូឈ្មោះស្រុកតំបែ ខេត្តកំពង់ចាម?

រិនៈ បាទ! ខេត្តកំពង់ចាម ទៅហ្នឹងប្រចាប់បង្កើតវរសេនាធំឯករាជ្យ ក្រោយមកបានបងសារឿននេះ គាត់ទៅប្រចាប់ចូលកងពល៨០១ ។

វណ្ណៈ៖ ចឹងឆ្នាំណាពូបានប្រចាប់ចូលក្នុងកងពល៨០១ហ្នឹង?

រិនៈ ឆ្នាំ៨៩តាមមើលឆ្នាំ៨៨អីហ្នឹង ។

វណ្ណៈ	ចឹងនៅកងពល៨០១តាសារឿន០៥?

រិនៈ	តាសារឿន តាកែវ ។

វណ្ណៈ	តាកែវ?

រិនៈ	ឥឡូវនៅលើប្រាសាទ ហើយតាលាង អុី លាង ។

វណ្ណៈ	អុី លាង?

រិនៈ	បាទ!អុី លាង ។

វណ្ណៈ	គាត់នៅរាល់ថ្ងៃ?

រិនៈ	នៅរាល់ថ្ងៃ ។

វណ្ណៈ	គាត់នៅណា?

រិនៈ	គាត់នៅផ្សារយើងទំនប់ដាច់ ឥឡូវពីការហើយ ។

វណ្ណៈ	ឈ្មោះ អុី លាង?

រិនៈ	អុី លាង ។

វណ្ណៈ	គាត់អនុដែរ?

រិនៈ	គាត់វង គាត់ផ្កាយ២ដែរ តែគាត់អាត្រែតអស់ហើយ គាត់មានដល់កហើយ ។

វណ្ណៈ	ចឹងគាត់មាន?

រិនៈ	ទំនប់ដាច់ហ្នឹងផ្សារហ្នឹងផ្សាររបស់គាត់ ដីគាត់តែថវិការបស់រដ្ឋ ។

វណ្ណៈ	ចឹងទៅដល់រកឈ្មោះ អុី លាង ចឹងគេស្គាល់ហើយ?

រិនៈ	បាទ!ផ្ទះគាត់ទៅឃើញហើយ ផ្ទះមួយធ្វើម៉ូតូហ្នឹង ផ្សាររោងគុយទាវគាត់ទៅមើលគាត់ដាក់រូប គាត់ផ្កាយ២ រូបថតបិតនៅហ្នឹង ។

វណ្ណៈ	ចឹងកាលពូនៅជាមួយតាសារឿន ហ្នឹងកម្លាំងពូចុះទៅខាងពង្រឹងទេ មិនមែនកម្លាំងវាយទេ?

រិនៈ	អត់មានបានវាយទេ ក្រោយមកបានចូលកងពល៨០១បានចាប់ផ្ដើមវាយ បែកកម្លាំងគ្នាជាវរៈអស់ហើយ ចាត់តាំងអស់ហើយចាប់ផ្ដើមវាយហើយហ្នឹង ។

វណ្ណៈ	ចឹងកាលហ្នឹងពូការហើយនៅ?

រិនៈ	ខ្ញុំមានប្រពន្ធមានកូនហើយហ្នឹង ។

វណ្ណៈ	ពូការនៅឆ្នាំណា?

រិនៈ	ឆ្នាំ៨៣ ។

វណ្ណៈ	ចឹងការនៅខាងម៉ាឡៃនោះទេ?

រិនៈ	ទេ ការនៅខាងព្រៃមាន់ ចម្ការគយើងនេះ ។

វណ្ណៈ៖ ចឹងការហើយប្រពន្ធនៅខាងក្រោយ?

រិនៈ បាទ ។

វណ្ណៈ៖ ចឹងពូចុះទៅម្តងៗរយៈពេលប៉ុន្មានបានមកជួបប្រពន្ធវិញ?

រិនៈ រយៈពេលពីរឆ្នាំទៅបីឆ្នាំនោះ ។

វណ្ណៈ៖ ចឹងចុះទៅយូរៗប្រពន្ធនៅក្រោយភ័យដែរ?

រិនៈ បាទ ។

វណ្ណៈ៖ ចឹងមុខព្រួញពូចុះទៅក្នុងកងពល៨០១ហ្នឹងវាយនៅម្តុំណា?

រិនៈ វាយម៉ាជួរព្រៃព្រីង បារាយណ៍ និយាយរួមទៅស្រុកតំបែរ ជុំវិញស្រុកតំបែរ ។

វណ្ណៈ៖ ចឹងនៅខាងតាប៉ាវពូស្គាល់ទេ?

រិនៈ ខ្ញុំវាយនៅខាងតាប៉ាវអីហ្នឹង ។

វណ្ណៈ៖ កម្លាំងនៅហ្នឹងច្រើនទេ?

រិនៈ កម្លាំងម៉ាកងពល៨០១ហ្នឹង បែកជាមុខសញ្ញាគ្នា ខ្លះមកបាធាយ ខ្លះមកទួលតាមុំ ខ្លះឡើងទៅខ្សែកក់ បង្ហើរខ្សែងចឹងទៅ ។

វណ្ណៈ៖ ចឹងគ្រាប់អាវុធអីយើងយកទៅយ៉ាងម៉េចបើឆ្ងាយសឹងអី?

រិនៈ ស្ពាយយកទៅគ្រាប់ គ្រាប់ទាំងកេះៗអាកា បេមាន១០គ្រាប់១៥គ្រាប់ មានអ្នកដឹកជញ្ជូនឲ្យទៀត ។

វណ្ណៈ៖ ចឹងអត់ខ្លាចចុះទៅជួបកម្លាំងខាងវៀតណាមអី?

រិនៈ តែប៉ះវាយហើយ វាយអស់គ្រាប់ឡើងយកគ្រាប់ទៀត គាដឹកឲ្យទៀត ។

វណ្ណៈ៖ ចឹងស្បៀងអាហារយើងអាចទាក់ទងទិញពីប្រជាជនបានឬយ៉ាងម៉េច?

រិនៈ ចុះលុយតា០៥ជាអ្នកកាន់ ។

វណ្ណៈ៖ ចឹងកាលហ្នឹងលុយច្រើនដែរ?

រិនៈ លុយប្រាក់ខែយើងម្នាក់៦០០បាត ។

វណ្ណៈ៖ ចឹងមានឲ្យប្រាក់ខែដែរ?

រិនៈ បាទ! គ្រាន់តែឲ្យក្នុងនាមទិញអង្ករហូប អត់មានឲ្យដាច់ទេណា ។

វណ្ណៈ៖ ចឹងមិនមែនបើកឲ្យយើងផ្ទាល់ខ្លួនទេ?

រិនៈ អត់ទេ បានតែមេៗទេ ។

វណ្ណៈ៖ លុយហ្នឹងឲ្យមែនតែមេកាន់ទាំងអស់?

រិនៈ បាទ!អ្នកកាន់អ្នកទិញអង្ករផ្សេង អត់មានឲ្យយកមកចាយទេ បើវាយវាចេះតែបានហើយ វាយកំចាត់កំចាយវាយទម្លាយរដ្ឋអំណាចវា ដូនកាលចាប់រដ្ឋអំណាចបុម្មួយចំផ្សារអីចឹងយក ខ្លះទៅ ចុះរបស់ជ័យភ័ណ្ឌ ។

វណ្ណៈ៖ កាលណាវាយបានកន្លែងណាយកកន្លែងហ្នឹងហើយ?

រិនៈ បាទ ។

វណ្ណៈ៖ ចឹងពូចុះទៅក្រោមដល់ឆ្នាំណាបានពូមកឡើងមកភ្នំដងរែកវិញ?

រិនៈ អត់ទៀតរឿងហ្នឹង ចុះដូនកាលមួយឆ្នាំពីរឆ្នាំបានឡើងមកម្តង ឡើងមកជួបជុំគ្រួសារ ។

វណ្ណៈ៖ ចឹងកាលមានអ៊ុនតាក់ចូលមកហ្នឹងសង្គ្រាមរឿងស្ងប់ហើយគេរកមកចរចារអីវិញចឹង ពេលហ្នឹងពូនៅហ្នឹងដដែលឬពូបានឡើងមកវិញហើយឆ្នាំ៩២-៩៣?

រិនៈ ខ្ញុំនៅហ្នឹងនៅសមរភូមិ ។

វណ្ណៈ៖ ឆ្នាំ១៩៩២-៩៣នៅហ្នឹងដែរ?

រិនៈ បាទ ។

វណ្ណៈ៖ ចឹងកាលហ្នឹងអ៊ុនតាក់ពូមានឃើញទេ កាលហ្នឹង?

រិនៈ ឃើញ ។

វណ្ណៈ៖ នៅខាងកំពង់ចាមហ្នឹង?

រិនៈ បាទ ។

វណ្ណៈ៖ យ៉ាងម៉េចបានគេមិនឲ្យកម្លាំងពូឡើងមកលើវិញ?

រិនៈ យើងចុះធ្វើការ ។

វណ្ណៈ៖ ចឹងនៅធ្វើការទៀត?

រិនៈ នៅធ្វើការ កាលហ្នឹងយើងមិននៅរកស៊ីឈើខ្លះ កងទ័ពអាឈើអាអីលក់ឲ្យប្រជាជន កាលហ្នឹងមានម៉ាស៊ីនរ៉ៃមានអី ។

វណ្ណៈ៖ ចឹងឆ្នាំ១៩៩៣ហ្នឹងនៅហ្នឹងរកស៊ីឈើដែរ?

រិនៈ បាទ!រកជាមួយក្រុមហ៊ុនខាងរដ្ឋកម្ពុជាដែលហ្នឹង ។

វណ្ណៈ៖ ចឹងកាលហ្នឹងពូមានបានបោះឆ្នោតទេ?

រិនៈ អត់ទេ ពួកខ្ញុំមានបានបោះណា គេមានឲ្យចូលស្រុកណា កាលហ្នឹងប្រទន់ប្រទាញកាលហ្នឹង គេស្អប់ខ្មែរក្រហម ។

វណ្ណៈ៖ ចឹងនៅពេលណាបានពូមកជួបមីងអីវិញ នៅឆ្នាំណាដែរ?

រិនៈ ឆ្នាំណាទេ ភ្លេចអស់ហើយខ្ញុំ ។

វណ្ណៈ៖ ចឹងពេលគេសម្លាប់តាសុន សេន អីកាលហ្នឹងពូមានឡើងមកនៅ កាលហ្នឹងមកឡើងមកនៅឆ្នាំ ៩០ជាងហើយ?

រិនៈ យី!កាលហ្នឹងសម្លាប់ខ្ញុំនៅក្នុងទេ ។

វណ្ណៈ៖ ចឹងកាលពូនៅក្នុងទៀត?

រិនៈ បាទ!មិនបាននៅនេះផង គេរកចាប់ប្រពន្ធយកដាក់គុកទៀតពេលហ្នឹង គេថាយើងភ្នាក់ងារបង ០៥អីណា ដៃជើង តាម៉ុក តាង៉ុន និងតាគេម អីហ្នឹងកាលជិនាន់ហ្នឹង បែកបក្សគ្នា ត្រឹមត្រពាំងប្រាសាទមកហ្នឹង០៥ ពីហ្នឹងទៅនោះតាម៉ុក ពួកតាគេម ពួកតាញ៉ុន តាង៉ុន អីហ្នឹងកាលជិនាន់ហ្នឹង គេចាត់ទុកពួកហ្នឹងថាពួកខ្មាំង ។

វណ្ណៈ៖ ចាត់ទុកខាង០៥?

រិនៈ បាទ!ពួកហ្នឹងមកកន្ទ្រាក់មីនក្បែរបាក់អន្លង់ពួកនៅអន្លង់វែង ។

វណ្ណៈ៖ ចឹងកាលសមាហរណ៍កម្មពូមកនៅហ្នឹងហើយតើ មិនមែននៅនោះទៀតណា?

រិនៈ ខ្ញុំមកហើយ ។

វណ្ណៈ៖ ចឹងការដឹកនាំចូលសមាហរណ៍កម្មហ្នឹងពូមានដឹងទេ ពីណាគេជាអ្នកផ្តួចផ្តើមអីចឹង?

រិនៈ អ្នកដឹកនាំចូលសមាហរណ៍កម្មមានតាលាង តាកែវ ។

វណ្ណៈ៖ មានតាលាង មានតាកែវ មានពីណាទៀត?

រិនៈ មានតែប៉ុណ្ណឹងទេ តាលាង គាត់អ្នកចូលមុនគេ ចូលដឹកនាំទ័ព តាកែវអីនៅខាងសាអែមបាន ទៅរៀនទៅអី ។

វណ្ណៈ៖ ចុះតាសយ តាជុំ ជាតិអីនោះ?

រិនៈ បាទ!មានតាសយ តាជុំ អីចូល កាលហ្នឹងកុំចូលទាន់កុំអីងាប់អស់ហើយពួកនេះ ។

វណ្ណៈ៖ ម៉េចចឹង?

រិនៈ តាម៉ុក យកសម្លាប់ចោល ហៅទៅរៀនតែមិនទៅ កុំអីស្លាប់អស់ពួកហ្នឹង ចេះបានភាសខ្លួនរួចអស់ ។

វណ្ណៈ៖ ចឹងពេលហ្នឹងពូរត់ទៅខាងណាទៅ?

រិនៈ ខ្ញុំមានរត់ទេ នៅហ្នឹង ។

វណ្ណៈ៖ ចឹងពូមកបោះទីតាំងភូមិកំណើតនៅហ្នឹង តាំងពីឆ្នាំណាទៅ?

រិនៈ ឆ្នាំ១៩៩១ ។

វណ្ណៈ៖ ចឹង៩១ពូនៅហ្នឹងរហូត?

រិនៈ បាទ!នៅបណ្តោយតាមមាត់អូរហ្នឹង កន្លែងនេះសុទ្ធតែកន្លែងយាយ នន ទេ ។

វណ្ណៈ៖ ចឹងភូមិហ្នឹងគេដាក់ឈ្មោះ តាំងពីពេលណាមក?

រិនៈ ភូមិតាំងពីសមាហរណ៍កម្មមក ។

វណ្ណៈ៖ ចឹងពីដើមអត់មានភូមិទេ?

រិនៈ ពីដើមគេហៅតែភូមិកន្ទ័ព ។

វណ្ណៈ៖ តាំងពីសម័យមុន?

រិនៈ សម័យមុនគេហៅថា បើខតាហរណ៍បើ៨១ហៅ៨១ចឹងទៅ ទួលចារចឹងទៅ បើទួលប្រាសាទ ៨៨ចឹងទៅ ៨៧ចឹងទៅ ហើយបើភូមិនេះ៨៥ចឹងទៅ គេហៅភូមិកន្ទ័ពចឹងណាស់ ។

វណ្ណៈ៖ ចឹងទំនប់ដាច់ហ្នឹង គេដាក់ឃុំទំនប់អីចឹង តើមានមូលហេតុការណ៍អី?

រិនៈ គេមានទំនប់គេ ទំនង ។

វណ្ណៈ៖ ចឹងពីណាធ្វើទំនប់ហ្នឹង?

រិនៈ តា០៥ គាត់អ្នកទប់ គេហៅទំនប់ដាច់ដាប់រហូតទៅ ។

វណ្ណៈ៖ ចឹងឮថាគេសម្លាប់តា០៥តា០៦ឮគេនិយាយថា គាត់ទៅសម្លាប់តាសុន សេន តាមពិតចឹងមែនឬយ៉ាងម៉េច?

រិនៈ ទេ មិនមែនទេ ។

វណ្ណៈ៖ ចឹងមិនមែនតា០៥ទៅសម្លាប់ទេ?

រិនៈ តា០៥គាត់មានទៅសម្លាប់អីគាត់ មានតែដៃជើងតាម៉ុក ទេ ។

វណ្ណៈ៖ ចឹងគេចោទ គាត់?

រិនៈ បាទ!គេចោទគាត់ ។

វណ្ណៈ៖ ហើយចាប់គាត់យកទៅសម្លាប់?

រិនៈ បាទ ។

វណ្ណៈ៖ ម៉េចបានគាត់មកចូលអន្ទាក់តាម៉ុក វិញ គាត់ជាប្រធានកងពលមួយផ្នែកធំដែរ អត់មានតស៊ូប្រឆាំង?

រិនៈ គាត់ជឿជាក់ដូចជាឪដែរ ដូចមាតាបីតាទៅហើយ គាត់មិនហៅទៅរៀន ហៅទៅរៀនទាក់កយកទៅសម្លាប់តែម្ដង ចុះអ្នកដឹកនាំទៅហើយ ចុះតា០៥និងតាម៉ុក ហ្នឹងជាជំនិតគាត់តាំងពីដើមមក ។

វណ្ណៈ៖ ចឹងគាត់មិននឹកស្មានថា ដល់ថ្នាក់ស្លាប់ចឹងទេ?

រិនៈ បាទៗ!តាហៅទៅអ្នកដឹកនាំតូចៗថា បងឯងមិនបាច់ទៅទេ តែទៅតាសម្លាប់មិនដឹងទេសង្ស័យណាស់ គាត់មិនជឿថាតាហ៊ានសម្លាប់អញទេ ទៅមែន ចូលអន្ទាក់មែន ។

វណ្ណៈ  ចឹងតាសានទៅដែរ?

រិនៈ  តាសាន ទៅដែរ ទាំងជនួងគាត់ហ្នឹង កូនចៅនៅរាល់ថ្ងៃហ្នឹង ក្មាយ៉ាប់ណាស់រឿងជីវភាព អត់ពីឪទៅ មានអីគ្មាគេយកទៅដាក់គុកអីដែរ ចេះរត់រួច កុំអីងាប់ដែលហ្នឹង ។

វណ្ណៈ  ចឹងចាប់ទាំងកូនយកទៅដាក់គុកដែរ?

រិនៈ  ចាប់ទាំងកូនអាវុធ អីហ្នឹង ។

វណ្ណៈ  ចឹងចេះរត់រួច?

រិនៈ  បាទ ។

វណ្ណៈ  ចឹងតា០៩គាត់មកនៅខាងត្រពាំងប្រាសាទហ្នឹង គាត់មានកសាងអីខ្លះដែរ?

រិនៈ  កសាងបានទំនប់នេះ ដុះទឹកហ្នឹងឥឡូវរុះអស់ ធ្វើថ្មីធ្វើមិនកើត ។

វណ្ណៈ  ចឹងមនុស្សគាត់យ៉ាងម៉េចដែលតាសារឿន?

រិនៈ  ចរិក គាត់ល្អណាស់ណាហ្នឹង ។

វណ្ណៈ  ចឹងតាម៉ុក ពូមានស្គាល់គាត់ទេ?

រិនៈ  តាម៉ុក ខ្ញុំមិនសូវស្និទ្ធទេ ។

វណ្ណៈ  ចឹងបើពូមើលទៅមនុស្សគាត់ចរិករបស់គាត់សាហាវឬជាមនុស្សធម្មតា?

រិនៈ  ទេ ចរិកគាត់ដូចជាធម្មតាទេតាម៉ុក មកពីដៃជើងគាត់ហ្នឹង ដៃជើងថាឲ្យសម្លាប់ៗហើយតាហ្នឹង ។

វណ្ណៈ  ចឹងគាត់ត្រចៀកស្រាលដែរ?

រិនៈ  គាត់ត្រចៀកស្រាលណាស់តាហ្នឹង ។

វណ្ណៈ  តែតាម៉ុក គាត់បានកសាងអីបានច្រើនទេ នៅខាងអន្លង់វែង?

រិនៈ  ច្រើនណាស់តាហ្នឹង ។

វណ្ណៈ  ពូថាគាត់កសាងផ្លូវបានច្រើន?

រិនៈ  បាទ!ផ្លូវតាមហ្នឹងគាត់តាមហ្នឹងមករហូត ។

វណ្ណៈ  ចឹងផ្លូវទៅព្រះវិហារអីហ្នឹង?

រិនៈ  បាទ ។

វណ្ណៈ  ចឹងកាលហ្នឹងអត់មានកៅស៊ូមានតែគ្រួសក្រហមអីចឹង?

រិនៈ  បាទ!មានតែគ្រួសក្រហម គាត់ធ្វើស្ពាន ដាក់លូ គ្រឿងចក្រគាត់ច្រើន ។

វណ្ណៈ  ចឹងថៃកាលហ្នឹងមិនសូវហ៊ានទេ?

រិនៈ ថៃមិនហ៊ានទេ គាត់ថាម៉េចចឹងហើយថៃ ថៃមិនហ៊ានទេ ខ្លាចគាត់ណាស់ ចុះគាត់យកក្មើសុទ្ធ តែនាយករដ្ឋមន្ត្រីអីនោះ លេងជាមួយតាម៉ុកម៉េចបាន ។

វណ្ណៈ ចឹងកាលហ្នឹងប្រាសាទព្រះវិហារអី ថៃមានឡើងមកលើហ្នឹងដែលឬមួយអត់ទេ?

រិនៈ អត់ទេ ។

វណ្ណៈ ចឹងអត់ហ៊ានទេ?

រិនៈ អត់ហ៊ានទេ ខ្លាចតាម៉ុកណាស់ ចឹងតាត្រឹម មិនក្មើគាត់ ។

វណ្ណៈ ចឹងគាត់មានក្មើជាមួយថៃទៀត?

រិនៈ បាទ ។

វណ្ណៈ ចឹងពូដឹងទេខាងព្រះវិហារអី កន្លែងម្តុំផ្ទះក្រហមអីហ្នឹង អាហ្នឹងជារបស់ថៃតាំងពីយូរមកឬមួយយ៉ាងម៉េច?

រិនៈ គេធ្វើជិនាន់ក្រោយទេ កាលមុនយើងនៅក្រៅជួរនោះ នៅក្នុងទៀតនោះ ។

វណ្ណៈ នៅក្នុងលើផ្ទះក្រហមទៀត?

រិនៈ បាទ! នៅក្រោមទៀត អាហ្នឹងវាខ្ពស់ទួលទេ នៅអាក្រោមនោះទៀតនោះ អាត្រពាំងមានដុះត្រាវអីហ្នឹង ។

វណ្ណៈ ចឹងខ្មែរក្រហមឈរនៅហ្នឹង?

រិនៈ បាទ! យើងដាក់ទ័ពអី ។

វណ្ណៈ ដីយើងទៅដល់ហ្នឹងចឹង?

រិនៈ បាទ ។

វណ្ណៈ ចឹងផ្ទះក្រហមហ្នឹងពីណាធ្វើ?

រិនៈ ថៃ ។

វណ្ណៈ ចឹងថៃធ្វើ?

រិនៈ បាទ! ថៃធ្វើជិនាន់ក្រោយនេះទេ យើងចូលជាមួយរាជ្យរដ្ឋាភិបាលហើយ ។

វណ្ណៈ ចឹងធ្វើសម័យក្រោយចូលជាមួយរដ្ឋាភិបាលសហការគ្នាមានបង់លុយចូលមើលអីហ្នឹង?

រិនៈ បាទ! កាលមុននៅតំបន់ខ្មែរក្រហមទេ យើងបេះតែឈូសគ្នាជាមួយ នរាវិទ្ធ អីចឹងវាបេះតែឈានចូលមកដល់រាល់ថ្ងៃហ្នឹង កាលនោះដីយើងទេ សុទ្ធតែឃ្លាំងតាម៉ុក គេហៅ១០០៣ ចាស់ ទៅខាងនោះទៀតឆ្ងាយណាស់ ទៅហួសថ្មលក្រហមទៀត តែឥឡូវទៅមើលគេយកដល់នេះអស់ហើយ យើងបេះតែឈូសគ្នាពេក ។

វណ្ណៈ ចឹងផ្ទៃក្នុងយើងបេះតែឈូសគ្នាពេកគេបេះទន្ទ្រានចូលបន្តិចម្តង?

រិនៈ	គេចូលបន្តិចម្តងទាល់តែអស់ យូរៗយើងអស់ភ្នំហើយ យើងឡើងទៅប៉ុង ។

វណ្ណៈ	ចឹងភ្នំយើងឡើងបានពាក់កណ្តាលទេ?

រិនៈ	បាទ! បានពាក់កណ្តាល ។

វណ្ណៈ	ចឹងពាក់កណ្តាលទៀតគេ?

រិនៈ	បាទ ។

វណ្ណៈ	ចឹងឥឡូវបើសិនជាយើងប្រៀបធៀបកាលមុន កាលមុនសមាហរណ៍កម្មនិងសមាហរណ៍កម្ម ហើយ ពូគិតថាមួយណារស់នៅមានលក្ខណៈស្រួលជាង?

រិនៈ	ឥឡូវស្រួលហើយ ។

វណ្ណៈ	កូនចៅបានរៀនសូត្របានធ្វើការ?

រិនៈ	កូនបានរៀនសូត្រ វាទាស់តែទាហាននិងក្រុមហ៊ុនយកដីហ្នឹង ។

វណ្ណៈ	ចឹងមានបញ្ហាទាហាននិងក្រុមហ៊ុនយកដី?

រិនៈ	ឥឡូវវាមានរឿងតែប៉ុណ្ណឹងទេ ឥឡូវ ។

វណ្ណៈ	ចុះខាងនិសិត្សគេចុះមកវាស់វែងអីនោះ ពូមានការទុកចិត្តបានទេ?

រិនៈ	វាស់ចេះតែវាស់ ។

វណ្ណៈ	តែគេមិនទាន់ចុះមកវាស់ណាហ្នឹង?

រិនៈ	វាស់ខ្លះហើយ វាស់ត្រឹមត្រឹមប៉ោង ។

វណ្ណៈ	តែឥឡូវពូថាចុះវាស់បន្តទៀតហើយ?

រិនៈ	មេឃុំគេមិនស៊ីញ៉េឲ្យគេក៏មិនហ៊ានដែរ ខ្លះមួយចំនួនមានទាហានយកតែម្តងនិងក្រុមហ៊ុន ។

វណ្ណៈ	ចឹងនៅមានបញ្ហាចឹងកើតឡើងខ្លះដែរ?

រិនៈ	បាទ! នេះមិនសូវអីទេ ខូចនៅត្រាំប៉ោងនោះ បាក់អន្ទង់ ។

វណ្ណៈ	ចឹងពូបើយើងមានបញ្ហាអីក្នុងសង្គមចឹង រឿងដោះស្រាយដីធ្លីឬមួយឈ្លសគ្នាចឹង យើងអាចពឹងពាក់ទៅលើផ្នែកច្បាប់បានទេរាល់ថ្ងៃ យើងមានទំនុកចិត្តលើច្បាប់ទេ?

រិនៈ	ទេ មិនដឹងជាយ៉ាងម៉េចទេ ខ្ញុំមិនសូវពាក់ព័ន្ធរឿងដីធ្លីហ្នឹងផង ។

វណ្ណៈ	ចឹងពូសង្ឃឹមថា ច្បាប់យើង អាចពឹងពាក់បានទេ ច្បាប់ទម្លាប់យើង បើសិនជាមានរឿងអី យើងអាចរត់ទៅរកច្បាប់បានទេ?

រិនៈ	រកចេះតែរកហើយ បើតុលាការរកតែលុយ ។

វណ្ណៈ	ចឹងពូមិនទាន់ជឿជាក់លើតុលាការទេ?

រិនៈ	សើច... ។

វណ្ណៈ	ចឹងពូនៅក្នុងភូមិយើងហ្នឹង យើងរាប់អានគ្នាយ៉ាងម៉េចដែលចំពោះអ្នកជិតខាង?
រិនៈ	អត់មានអីទេ ។
វណ្ណៈ	ចឹងមានខាងអង្គការក្រៅរដ្ឋាភិបាលគេមកបង្រៀនខាងផ្នែកកសិកម្មមានទេ?
រិនៈ	មាន ចិញ្ចឹមជ្រូក ចិញ្ចឹមមាន់ ដាំបន្លែដាំអី ។
វណ្ណៈ	ចឹងការចុះមកអប់រំចឹងជាការល្អដែលទេ?
រិនៈ	បាទ!ល្អម្យ៉ាងដែលបានជួយលើកស្ទួយយើង ។
វណ្ណៈ	ពូមានធ្លាប់ចូលរួមទេ?
រិនៈ	ចូលដែលហ្នឹង ។
វណ្ណៈ	ចឹងដូចជាបញ្ហានៅក្នុងគ្រួសារ ឧបមាថា បើយើងត្រូវធ្វើស្រែចម្ការមួយឆ្នាំទៅមួយឆ្នាំ ពូមានដែលពិភាក្សាជាមួយប្រពន្ធពូឬកូនចៅពូថាយើងត្រូវធ្វើអីខ្លះក្នុងឆ្នាំហ្នឹង ចឹងពូមានដែលបានពិភាក្សាទេ ក្នុងករណីបែបហ្នឹង?
រិនៈ	ធ្វើអីមួយត្រូវតែពិភាក្សា ។
វណ្ណៈ	ចឹងមានពិភាក្សាញឹកញាប់ទេ?
រិនៈ	បាទ!ពិភាក្សារឿងដាំស្រូវធ្វើនេះធ្វើនោះ ដាំសណ្តែកសៀងដាំដំឡូងចឹងទៅ យើងកសិករមានអីមានតែប៉ុណ្ណឹង ។
វណ្ណៈ	ចឹងផលិតផលទាំងអស់ហ្នឹងបើយើងធ្វើបានហើយ ចឹងក្នុងការលក់ដូរបានស្រួលដែលឬមួយវាពិបាកលក់ចេញ?
រិនៈ	ទេ មិនពិបាកទេ ។
វណ្ណៈ	តម្លៃបានគួសមដែលឬមួយយ៉ាងម៉េច?
រិនៈ	បាទ!យើងបាន២២អីចឹងដែរ ។
វណ្ណៈ	ចឹងដំឡូវអី?
រិនៈ	ដំឡូងឥឡូវពូថាបាន៧០០ ក្នុងមួយគីឡូដំឡូងក្រៀម ។
វណ្ណៈ	ចឹងនៅក្នុងស្រុកហ្នឹងគេដាំអីច្រើនជាងគេ?
រិនៈ	ដាំដំឡូងឬមួយសណ្តែកសៀងនិងសណ្តែកបាយនិងស្រូវប៉ុណ្ណឹងវាមានបួនមុខនិងបន្លែបន្តុ ។
វណ្ណៈ	ចឹងជីវភាពគ្រួសារពូរាល់ថ្ងៃយ៉ាងម៉េចដែរ?
រិនៈ	ខ្ញុំមធ្យមទេខ្ញុំ រស់នៅស្រួលមិនលំបាក មានរបស់របរប្រើប្រាស់គ្រប់គ្រាន់ ។
វណ្ណៈ	ចឹងវត្តអារាមមានច្រើនទេ នៅក្នុងស្រុកយើង?
រិនៈ	មានច្រើនណាស់ និយាយរឿងវត្ត ចង់គ្រប់ឃុំហើយ ។

វណ្ណៈ	ចឹងពូកាន់សាសនាអីដែលរាល់ថ្ងៃ?

រិនៈ	ខ្ញុំសាសនាព្រះពុទ្ធហើយ ។

វណ្ណៈ	ចឹងពូយល់យ៉ាងម៉េចដែលសាសនាព្រះពុទ្ធពូ?

រិនៈ	យើងពីដូនតាមកយើងត្រូវគោរពសាសនាព្រះពុទ្ធ ព្រះពុទ្ធមិនឲ្យសម្លាប់មិនឲ្យលួចមិនឲ្យប្លន់ មិនឲ្យមានការកាប់សម្លាប់ត្រូវទៀងត្រង់ ។

វណ្ណៈ	ចឹងពូជឿថាមានបុណ្យបាបទេ?

រិនៈ	ទេ តែយើងធ្វើអាក្រក់មានបាបហើយ បើសាសនាអីផ្សេងៗខ្ញុំមិនសូវជឿទេ ខ្ញុំជឿតែសាសនាព្រះពុទ្ធតាំងពីបុរាណរបស់ខ្មែរយើងត្រូវតែគោរពហើយ ។

វណ្ណៈ	ចឹងទំលាមទំលាប់ប្រពៃណីយើងទៅភ្ជុំបិណ្យទៅវត្តអីតាមធម្មតា?

រិនៈ	បាទ!សាសនាយ៉េស៊ូអីខ្ញុំមិនត្រូវទេ ។

វណ្ណៈ	ចឹងការស្លៀកពាក់កូនចៅយើងសម័យឥឡូវហ្នឹង បើប្រៀបធៀបសម័យកាលមុនមានការខុសគ្នាដែលពូ?

រិនៈ	ខុសប្លែកក្មេងៗឥឡូវ ។

វណ្ណៈ	ខុសយ៉ាងម៉េចទៅ?

រិនៈ	ខុសនិងខោអាវស្ទុទ្ធតែកាត់យកម៉ូតគេចឹងទៅ ក្មេងៗបើខ្ញុំធម្មតាទេ ។

វណ្ណៈ	ចឹងការស្លៀកពាក់មានការផ្លាស់ប្តូរខ្លាំង?

រិនៈ	វាតាមសម័យ ។

វណ្ណៈ	ចឹងកាលសម័យខ្មែរក្រហមមានទេ វត្តអាប្រពៃណីអី មានទំលាមទំលាប់បែបហ្នឹងមានទេ?

រិនៈ	មិនមានទេ មានអីគោរពអីណាមានតែវាយយួនអីហ្នឹង មានវត្តមានអាអីណា ។

វណ្ណៈ	ចឹងពូយល់យ៉ាងម៉េចដែលប្រទេសមួយមានអ្នកដឹកនាំមិនឲ្យគោរពសាសនាចឹង ពូគិតថាល្អដែលអត់?

រិនៈ	មិនល្អទេ មិនគិតរឿងបាបបុណ្យអី ចឹងបានមានការកាប់សម្លាប់គ្នា ។

វណ្ណៈ	ចឹងដូចពូចឹងខំតស៊ូចឹង ឆ្លងកាត់ឧបសគ្គគ្រប់បែបយ៉ាងទាំងអស់ តែទីបញ្ចប់ដូចថាមិនបានទទួលផលអីធំដុំអីចឹង តើពូមានតូចចិត្តនិងការតស៊ូធ្វើចលនាហ្នឹងដែលអត់?

រិនៈ	តូចចិត្តហើយតែមិនដឹងធ្វើម៉េច បើវាចឹងទៅហើយ វាទូទៅចឹងទៅហើយ បើយើងមិនតាមគេស្លាប់ ។

វណ្ណៈ	បាទ ។

រិនៈ ម្ចោះហើយតាមគេតាមឯងគេដឹកនាំទៅចឹងហើយ បើយើងតូចចិត្តមិនធ្វើយើងនៅផ្ទះក៏មិនសុខ ត្រូវតែធ្វើតាមគេ ព្រោះយើងប្រឆាំងគេស្លាប់ឥឡូវ គេសម្លាប់យើងចោលទៅ ថាយើងជីបេយួនអី ។

វណ្ណៈ ចឹងដូចថារាល់ថ្ងៃហ្នឹងមានរោងចក្រគេមកវិនិយោគនៅជិតហ្នឹងឬនៅ?

រិនៈ នៅទេ ។

វណ្ណៈ ចឹងមិនទាន់មានរោងចក្រអីទេ?

រិនៈ បាទ! រោងចក្រពួគេថាប្រុងបង្កើតដែរ រោងចក្រម្សៅមី រោងចក្រកាត់ដេរ ។

វណ្ណៈ ចឹងបើសិនមានរោងចក្រអីកើតមាននៅហ្នឹង ពូគិតថាប្រជាជនរស់នៅហ្នឹងអាចមានជីវភាពរស់នៅល្អជាងហ្នឹងមួយកំរិតទៀតទេ?

រិនៈ ទេ បើសិនបានបង្កើតប្រជាពលរដ្ឋរិតតែមានការរីកចំរើនហើយ ។

វណ្ណៈ បាទ ។

រិនៈ បើសិនយើងដាំអីទៅមានរោងចក្រគេទិញ ទាក់ទងនិងពាណិជ្ជកម្មទៅវិញទៅមក ហើយកូនចៅយើងក៏បានធ្វើការងាររមិនបាច់ទៅឆ្ងាយ ខ្លះទៅរហូតដល់ថៃអី ខ្លះទៅម៉ាឡេ ខ្លះទៅរហូតដល់ស្លាប់ខ្លួនក៏មានដែរ ។

វណ្ណៈ ចឹងរាល់ថ្ងៃកូនចៅពូមានរៀបចំគ្រួសារបានខ្លះហើយបែកផ្ទះសំបែងខ្លះហើយ?

រិនៈ មានគ្រួសារខ្លះនៅក្នុងបន្ទុកខ្លះ ។

វណ្ណៈ ចឹងខ្ញុំអរគុណពូច្រើនហើយ តើពូមានអីបន្ថែមទេ នូវអ្វីដែលខ្ញុំមិនបាន់បានសួរពូ ពូមានចង់និយាយអីបន្ថែមទេ?

រិនៈ ខ្ញុំអត់មានអីទេ មានតែប៉ុណ្ណឹង ។

វណ្ណៈ ចឹងអរគុណពូច្រើនហើយ ។

រិនៈ បាទ ។

**ចប់**